# មាតិកា

## I- ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


២២-២-២០០០ -ព្រះរាជក្រឹត្យ ជស/រកត/០២០០/១០៥ ស្ដីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ ៣៥១


## II- រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ


២២-២-២០០០ -អនុក្រឹត្យលេខ ៦៩ អនក្រ.តត ស្ដីពីការជូនមេដាយការងារ ៣៤៩

២២-២-២០០០ -អនុក្រឹត្យលេខ ៧០ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៣៥២

២២-២-២០០០ -អនុក្រឹត្យលេខ ៧១ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៣៥៣

២២-២-២០០០ -អនុក្រឹត្យលេខ ៧២ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ ៣៥៤

២៣-២-២០០០ -អនុក្រឹត្យលេខ ៧៣ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ ៣៥៥

២៣-២-២០០០ -អនុក្រឹត្យលេខ ៧៤ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ ៣៥៦

២៣-២-២០០០ -អនុក្រឹត្យលេខ ៧៥ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ ៣៥៧

២៣-២-២០០០ -អនុក្រឹត្យលេខ ៧៦ អនក្រ.តត ស្ដីពីការបញ្ឈប់ និងផ្ទេរភារកិច្ចមុខតំណែងអភិបាលរងខេត្ត-ក្រុង ៣៥៧

២៣-២-២០០០ -អនុក្រឹត្យលេខ ៧៧ អនក្រ.តត ស្ដីពីការតែងតាំងអភិបាលរងខេត្ត ក្រុង ៣៥៨

២៣-២-២០០០ -អនុក្រឹត្យលេខ ៧៨ អនក្រ.តត ស្ដីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៣៥៩

២៣-២-២០០០ -អនុក្រឹត្យលេខ ៧៩ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៣៦០

២៣-២-២០០០ -អនុក្រឹត្យលេខ ៨០ អនក្រ.តត ស្ដីពីការជូនមេដាយការងារ ៣៦១

២៣-២-២០០០ -អនុក្រឹត្យលេខ ៨១ អនក្រ.តត ស្ដីពីការជូនមេដាយការងារ ៣៦២


### ២-សេចក្ដីសម្រេច


១៦-០២-២០០០ -សេចក្ដីសម្រេចលេខ ១៣ សសរ. ស្ដីពីការផ្ទេរសិទ្ធិនៃរាជរដ្ឋាភិបាល ៣៦៥


## II- ការិយាល័យក្រសួង

### ១- ធនាគារជាតិ នៃកម្ពុជា

#### ប្រកាស


១៦-០២-២០០០ -ប្រកាសលេខ ធ ៧-០០-៤៦ ប្រក. ស្ដីពីអនុបាតសាធនភាពរបស់ធនាគារ ៣៦៦

៦-០២-២០០០ -ប្រកាសលេខ ធ ៧-០០-៤៧ ប្រក. ស្តីពីការគណនាមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ ៣៧១

៧-០២-២០០០ -ប្រកាសលេខ ធ ៧-០០-៥០ ប្រក. ស្តីពីដំណើការគណនេយ្យកម្មសំរាប់ប្រតិបត្តិការរូបិយប័ណ្ណ ៣៧៥

៧-០២-២០០០ -ប្រកាសលេខ ធ ៧-០០-៥១ ប្រក. ស្តីពីចំណាត់ថ្នាក់ និងសំវិធានធន់លើបំណុលអាក្រក់និងបំណុលសង្ស័យរួមទាំងការ ប្រាក់ដែលកានព្យួរ ៣៧៨

៧-០២-២០០០ -ប្រកាសលេខ ធ ៧-០០-៥២ ប្រក. ស្តីពីការត្រួតពិនិត្យ ហានិភ័យធំៗ របស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ៣៨២

## ២– ទីស្តីការរដ្ឋមន្ត្រីក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល

### ប្រកាស

៦-០២-២០០០ -ប្រកាសលេខ ១០៥ កឧ.ប្រក. អនុញ្ញាតឲ្យក្រុមហ៊ុន អ៊ីមអេសអ៊ិនធើណេសិនណលប្លាមេន ខមភេនី តំណាងដោយលោក KIM DO SAM សញ្ជាតិ កូរ៉េ បង្កើតរោងចក្រកាត់ដេរ សំលៀកបំពាក់នាំចេញ ៣៨៤

## ៣– ទីស្តីការរដ្ឋមន្ត្រីក្រសួង ប្រៃសណីយ៍ និងទូរគមនាគមន៍

### ប្រកាស

២-០២-២០០០ -ប្រកាសលេខ ០២៤ បទ.ប្រក. ស្តីពីការតភ្ជាប់រវាងប្រព័ន្ធទូរស័ព្ទ ៣៨៦

# I- ខុទ្ទកាល័យព្រះមហាក្សត្រ

## ព្រះរាជក្រឹត្យ

### ព្រះរាជក្រឹត្យ ជស/រកត/០២០០/១០៤

### ស្ដីពីសហលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌ មន្ត្រីរដ្ឋបាលក្រសួងមហាផ្ទៃ

យើង

ព្រះបាទសម្ដេចព្រះ នរោត្ដម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

***

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ ១៩៩៧ ស្ដីពីគោល ការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី ១១ ខែកុម្ភៈ ឆ្នាំ២០០០

## គ្រាស់បន្ទាប់
## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

មាត្រា ១ ._

ត្រូវបានបង្កើតក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ របស់ក្រសួងមហាផ្ទៃ ដែលត្រូវបានចាត់ថ្នាក់ក្នុងប្រភេទ ក ដូចមានចែងក្នុងមាត្រា ៣ នៃព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ ។

មាត្រា ២._

មន្ត្រីរាជការនៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់នេះ ត្រូវស្ថិតនៅក្រោមឱវាទក្រសួងមហាផ្ទៃ ។

មាត្រា ៣._

មន្ត្រីរាជការនៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់មានភារកិច្ច ក្នុងការរៀបចំ និងអនុវត្តគោលនយោបាយរាជរដ្ឋាភិបាលក្នុងសមត្ថកិច្ចក្រសួងមហាផ្ទៃ ព្រមទាំងធានាដំណើរការដឹកនាំគ្រប់គ្រងអង្គភាពរដ្ឋបាលនានា នៅថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋាន ។ មន្ត្រីរាជការនៃក្របខ័ណ្ឌនេះមានឧបនិស្ស័យក្នុងការបំពេញមុខងារក្នុងតំណែងដឹកនាំ អធិការកិច្ច សិក្សា និងផ្តល់យោបល់ និងរាល់តំណែងទទួលខុសត្រូវ ។

## ជំពូកទី ២
## ឋានន្តរសក្តិ ថ្នាក់ និង មុខតំណែងក្របខ័ណ្ឌ

មាត្រា ៤._

ក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់មាន ៣ ឋានន្តរសក្តិ :

- ឧត្តមមន្ត្រី : មាន ៦ ថ្នាក់
- វរៈមន្ត្រី : មាន ១០ ថ្នាក់
- អនុមន្ត្រី : មាន ១៤ ថ្នាក់ ។

មាត្រា ៥._

មន្ត្រីរាជការក្នុងឋានន្តរសក្តិឧត្តមមន្ត្រី មានឧបនិស្ស័យសំរាប់កាន់មុខតំណែងជា :

- អគ្គនាយក
- អគ្គាធិការ
- អភិបាលខេត្ត-ក្រុង

និង មុខតំណែងឯទៀតដែលមានថ្នាក់ស្មើនឹងមុខតំណែងខាងលើ ដែលមាននៅក្នុងរចនាសម្ព័ន្ធរបស់ក្រសួងមហាផ្ទៃ ។

មន្ត្រីរាជការក្នុងឋានន្តរស័ក្តិវរៈមន្ត្រី មានឧបនិស្ស័យសំរាប់កាន់មុខតំណែងជា :

- អគ្គនាយករង
- អគ្គាធិការរង
- ប្រធាននាយកដ្ឋាន
- អភិបាលរងខេត្ត-ក្រុង

និង មុខតំណែងឯទៀតដែលមានថ្នាក់ស្មើនឹងមុខតំណែងខាងលើ ដែលមាននៅក្នុងរចនាសម្ព័ន្ធរបស់ក្រសួងមហាផ្ទៃ។

មន្ត្រីរាជការក្នុងឋានន្តរស័ក្តិអនុមន្ត្រី មានឧបនិស្ស័យសំរាប់កាន់មុខតំណែង :

- អនុប្រធាននាយកដ្ឋាន
- អភិបាលស្រុក-ខ័ណ្ឌ

និងមុខតំណែងឯទៀតដែលមានថ្នាក់ស្មើនឹងមុខតំណែងខាងលើ ដែលមាននៅក្នុងរចនាសម្ព័ន្ធរបស់ក្រសួងមហាផ្ទៃ ។

## ជំពូកទី ៣

## ការជ្រើសរើស

**មាត្រា ៦.-**

ការជ្រើសរើសបញ្ចូលក្នុងក្របខ័ណ្ឌ ត្រូវធ្វើតាមរយៈការប្រឡងប្រជែង ក្នុងចំណោមមន្ត្រីរាជការ ឬ និងក្នុងចំណោមនិស្សិត ។ ចំនួននៃតំណែងដែលត្រូវផ្តល់ក្នុងការប្រឡងប្រជែងសំរាប់មន្ត្រីរាជការ និង និស្សិត ត្រូវកំណត់ ដោយអាជ្ញាធរដែលមានសមត្ថកិច្ចតាមសំណើរបស់ក្រសួងមហាផ្ទៃ ។

**មាត្រា ៧.-**

ការប្រឡងប្រជែងក្នុងចំណោមនិស្សិត ត្រូវធ្វើចំពោះបេក្ខជនដែលមានសញ្ញាប័ត្រយ៉ាងទាបបរិញ្ញាប័ត្រនីតិសាស្ត្រ បរិញ្ញាប័ត្រសេដ្ឋកិច្ច ឬសញ្ញាប័ត្រដែលមានតំលៃស្មើ និងមានអាយុយ៉ាងច្រើន ៣០ ឆ្នាំ គិតរហូតដល់ថ្ងៃប្រឡង ។

បេក្ខជនដែលត្រូវបានជ្រើសរើសតាមរយៈការប្រឡងប្រជែងក្នុងចំណោមមន្ត្រីរាជការផ្ទៃក្នុង ត្រូវធ្វើ ចំពោះមន្ត្រីរាជការដែលស្ថិតយ៉ាងទាបបំផុតក្នុងថ្នាក់លេខ ១១ របស់ក្របខ័ណ្ឌប្រភេទ ខ និង មានអាយុ យ៉ាងច្រើន ៤៥ ឆ្នាំ ។

ចំពោះមន្ត្រីរាជការរបស់ក្រសួងមហាផ្ទៃ ដែលមានសញ្ញាប័ត្រសមមូលនឹងបរិញ្ញាប័ត្រ អាចប្រលងចូលក្នុងក្របខ័ណ្ឌនេះបាន ដោយពុំគិតពីល័ក្ខខ័ណ្ឌ ឋានន្តរសក្តិ និង ប្រភេទក្របខ័ណ្ឌឡើយ ហើយមានអាយុយ៉ាងច្រើនបំផុត ៤៥ ឆ្នាំ ។

ការបណ្តុះបណ្តាលដំបូងត្រូវធ្វើតាមរយៈសាលាភូមិន្ទរដ្ឋបាល ។

## ជំពូកទី ៤

## កម្មសិក្សា និង ការតាំងស៊ប់

មាត្រា ៨._

បន្ទាប់ពីការបណ្តុះបណ្តាលដំបូង សិស្សមន្ត្រីរដ្ឋបាលជាន់ខ្ពស់ត្រូវបានចាត់ឲ្យទៅបំពេញការងារតាមអង្គភាពនានាក្រោមឱវាទក្រសួងមហាផ្ទៃ ហើយត្រូវបានតែងតាំងជាមន្ត្រីរដ្ឋបាលជាន់ខ្ពស់កម្មសិក្សា ដោយប្រកាសរបស់ក្រសួងមហាផ្ទៃ ។ មន្ត្រីកម្មសិក្សាទាំងនេះ ត្រូវឆ្លងកាត់កម្មសិក្សាមួយដែលមានរយៈពេលដូចខាងក្រោម :

១- ១២ ខែ ចំពោះមន្ត្រីដែលត្រូវជ្រើសរើសចេញមកពីនិស្សិត ។

២- ០៦ ខែ ចំពោះមន្ត្រីដែលត្រូវបានជ្រើសរើសចេញមកពីមន្ត្រីរាជការហើយដែលពីមុននេះពុំស្ថិតក្នុងក្របខ័ណ្ឌក្រមការ ។

ចំពោះមន្ត្រីដែលត្រូវបានជ្រើសរើសចេញមកពីមន្ត្រីរាជការ ហើយដែលពីមុននេះស្ថិតក្នុងក្របខ័ណ្ឌមន្ត្រីក្រមការរបស់ក្រសួងមហាផ្ទៃ ពុំចាំបាច់ឆ្លងកាត់កម្មសិក្សាសាកល្បងឡើយ ។

ក្រោយពេលធ្វើកម្មសិក្សាសាកល្បង មន្ត្រីដែលចែងក្នុងចំណុចទី១ និង ទី២ ខាងលើត្រូវបានតាំងស៊ប់ក្នុងឋានន្តរសក្តិអនុមន្ត្រី ។ ក្នុងករណីពិសេសអាចត្រូវបានអនុញ្ញាតអោយធ្វើកម្មសិក្សាបន្តបន្ថែមដែលមានរយៈពេលអតិបរមាត្រឹម ១២ ខែ ចំពោះមន្ត្រីដែលមានចែងក្នុងចំណុចទី១ និង ០៦ ខែ ចំពោះមន្ត្រីដែលមានចែងក្នុងចំណុចទី២ ។ មន្ត្រីដែលពុំបានទទួលជោគជ័យក្នុងការបំពេញកម្មសិក្សាបន្ថែមនេះ ត្រូវលុបឈ្មោះចោលប្រសិនបើចេញមកពីនិស្សិត ឬមួយបញ្ចូលទៅក្របខ័ណ្ឌដើមវិញប្រសិនចេញមកពីមន្ត្រីរាជការ ដោយគិតបញ្ចូលសំរាប់អតីតភាព ការងារ ។ ករណីខាងលើទាំងនេះត្រូវសំរេចដោយប្រកាសរបស់ក្រសួងមហាផ្ទៃ ហើយត្រូវធ្វើឡើងក្នុងរយៈពេលយ៉ាងយូរ ៣ខែ ក្រោយការបញ្ចប់កម្មសិក្សា ។

មន្ត្រីរដ្ឋបាលជាន់ខ្ពស់ ដែលត្រូវបានជ្រើសរើសតាមការប្រឡងប្រជែងក្នុងចំណោមនិស្សិតត្រូវបញ្ចូលទៅក្នុងថ្នាក់ទី១៤ នៃឋានន្តរសក្តិអនុមន្ត្រី ។

មន្ត្រីរដ្ឋបាលជាន់ខ្ពស់កម្មសិក្សាដែលត្រូវបានជ្រើសរើសតាមការប្រលងប្រជែងក្នុងចំណោម មន្ត្រីរាជការត្រូវបញ្ចូលទៅ ក្នុងថ្នាក់ដែលមានសន្ទស្សន៍បៀវត្សរ៍ខ្ពស់ លើបន្ទាប់ពីសន្ទស្សន៍ចាស់របស់ គាត់ខ្លួន ។

ការតាំងស៊ប់ក្នុងឋានន្តរសក្តិអនុមន្ត្រីនៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ត្រូវធ្វើឡើងដោយព្រះ រាជក្រឹត្យ ។

## ជំពូកទី ៥

## ការតែងតាំង

**មាត្រា ៩.-**

ក្រោយពេលត្រូវបានតាំងស៊ប់ក្នុងឋានន្តរសក្តិមួយរួចហើយ មន្ត្រីរដ្ឋបាលជាន់ខ្ពស់ទាំងនេះ អាច ត្រូវបានតែងតាំងក្នុងមុខតំណែងទំនេរណាមួយ ដូចមានចែងក្នុងមាត្រា ៥ ខាងលើស្របតាមឋានន្តរសក្តិ របស់ខ្លួន តាមបែបបទដូចបានកំណត់ក្នុងមាត្រា ១៤ និង មាត្រាបន្តបន្ទាប់នៃព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈ រដ្ឋមន្ត្រី ។

## ជំពូកទី ៦

## ការតម្លើងថ្នាក់ និង ការតម្លើងឋានន្តរសក្តិ

**មាត្រា ១០.-**

មន្ត្រីនៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ត្រូវបានតម្លើងថ្នាក់ទៅតាមលក្ខខណ្ឌដូចបានចែងក្នុង មាត្រា ២០ និង មាត្រាបន្តបន្ទាប់នៃព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពី សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ។

លក្ខណៈសម្បត្តិជាមូលដ្ឋានដែលត្រូវពិនិត្យតម្លើងថ្នាក់មានដូចខាងក្រោម :

- មានគំនិតផ្តួចផ្តើមនិងច្នៃប្រឌិត
- មានស្មារតីទទួលខុសត្រូវ
- យកចិត្តទុកដាក់លើផលប្រយោជន៍ និងដល់កិត្តិយសក្រសួង
- មានប្រសិទ្ធភាពក្នុងការដឹកនាំ
- មានសីលធម៌ល្អ

ការឡើងថ្នាក់នៃអ្នករាជការក្នុងក្របខ័ណ្ឌនេះត្រូវគិតក្នុងសមាមាត្រ ៣/៤ តាមវេនជ្រើសរើស និង ១/៤ តាមវេនអតីតភាព ។

ចំពោះការតំឡើងថ្នាក់ ៖

- ការតម្លើងថ្នាក់ក្នុងឋានន្តរសក្តិឧត្តមមន្ត្រី ត្រូវសំរេចដោយព្រះរាជក្រឹត្យ
- ការតម្លើងថ្នាក់ក្នុងឋានន្តរសក្តិវរៈមន្ត្រី ត្រូវសំរេចដោយអនុក្រឹត្យ
- ការតម្លើងថ្នាក់ក្នុងឋានន្តរសក្តិអនុមន្ត្រី ត្រូវសំរេចដោយប្រកាសរបស់ក្រសួងមហាផ្ទៃ ។

**មាត្រា ១១._**

គោលការណ៍នៃការតម្លើងឋានន្តរសក្តិ តាមធម្មតាត្រូវតម្លើងទៅក្នុងថ្នាក់ដំបូងនៃឋានន្តរសក្តិខ្ពស់លើបន្ទាប់ឬក្នុងករណីចាំបាច់ ត្រូវតម្លើងទៅក្នុងថ្នាក់ដែលស្របជាមួយសន្ទស្សន៍ខ្ពស់លើបន្ទាប់ពីសន្ទស្សន៍ចាស់របស់មន្ត្រីសាមី ។

ការតម្លើងឋានន្តរសក្តិ ត្រូវអនុវត្តអោយបានស្របជាមួយចំនួនតំណែងដែលទំនេរនៅក្នុងឋានន្តរសក្តិនោះហើយ ត្រូវធ្វើតាមរយៈការចុះឈ្មោះក្នុងតារាងតម្លើងឋានន្តរសក្តិ ឬតាមរយៈការប្រឡងប្រជែង ឬមួយតាមរយៈការបណ្តុះបណ្តាលរយៈពេលវែងនៅក្នុង ឬក្រៅប្រទេស ។

ការតម្លើងឋានន្តរសក្តិពីអនុមន្ត្រី ទៅវរៈមន្ត្រីត្រូវសំរេចដោយអនុក្រឹត្យ ហើយការតម្លើងឋានន្តរសក្តិពីវរៈមន្ត្រីទៅឧត្តមមន្ត្រីត្រូវសំរេចដោយព្រះរាជក្រឹត្យ ។

**មាត្រា ១២._**

អាចតម្លើងទៅក្នុងឋានន្តរសក្តិវរៈមន្ត្រីគឺមន្ត្រីទាំងឡាយដែលបានឡើងដល់ថ្នាក់លេខ ១១ នៃឋានន្តរសក្តិអនុមន្ត្រី ។

អាចតម្លើងទៅក្នុងឋានន្តរសក្តិឧត្តមមន្ត្រីទាំងឡាយដែលបានឡើងដល់ថ្នាក់លេខ ៧ នៃឋានន្តរសក្តិវរៈមន្ត្រី ។

ការតម្លើងទៅក្នុងឋានន្តរសក្តិមួយខ្ពស់ជាង អាចផ្តល់ឧបនិស្ស័យដល់មន្ត្រីសាមីសំរាប់កាន់មុខតំណែងស្របតាមឋានន្តរសក្តិថ្មីនោះ ដូចបានកំណត់ក្នុងមាត្រា ៥ នៃលក្ខន្តិកៈដោយឡែកនេះ ។

**មាត្រា ១៣._**

សន្ទស្សន៍សំរាប់ថ្នាក់ ក្នុងឋានន្តរសក្តិនីមួយៗ នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ និងតម្លៃឯកត្តានៃសន្ទស្សន៍ព្រមទាំងរបបលាភការផ្សេងៗ ទៀត ត្រូវកំណត់ដោយព្រះរាជក្រឹត្យដោយឡែក ។

## ជំពូកទី ៧
## បទប្បញ្ញត្តិដោយឡែក

**មាត្រា ១៤._**

មន្ត្រីនៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ បន្តបំពេញការងាររដ្ឋបាលរហូតដល់អាយុ ៦០ ឆ្នាំ ទើបចូលនិវត្តន៍ ។

ចំពោះការដាក់អោយចូលនិវត្តន៍ :

- ការដាក់អោយចូលនិវត្តន៍នៅក្នុងឋានន្តរសក្តិឧត្តមមន្ត្រី ត្រូវសំរេចដោយព្រះរាជក្រឹត្យ
- ការដាក់អោយចូលនិវត្តន៍នៅក្នុងឋានន្តរសក្តិវរៈមន្ត្រី ត្រូវសំរេចដោយអនុក្រឹត្យ
- ការដាក់អោយចូលនិវត្តន៍នៅក្នុងឋានន្តរសក្តិអនុមន្ត្រី ត្រូវសំរេចដោយប្រកាស ។

មាត្រា ១៥ ._ មន្ត្រីនៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ដែលមានសញ្ញាប័ត្រខ្ពស់ជាងបរិញ្ញាប័ត្រ ត្រូវតម្លើងថ្នាក់មួយថ្នាក់ជាស្វ័យប្រវត្តិ ។

មាត្រា ១៦._ សញ្ញាសក្តិ និង ឯកសណ្ឋានសំរាប់មន្ត្រីរដ្ឋបាលជាន់ខ្ពស់ ត្រូវកំណត់ដោយព្រះរាជក្រឹត្យមួយដោយឡែក ។

## ជំពូកទី ៨

## អន្តរប្បញ្ញត្តិ

មាត្រា ១៧._

ចំនួនដំបូងនៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ត្រូវកសាងចេញពីសមាហរណកម្មនៃមន្ត្រីរាជការទាំងឡាយដែលបច្ចុប្បន្នកំពុងបំពេញមុខតំណែង និងមុខងារពិតប្រាកដរបស់ក្របខ័ណ្ឌក្នុងរដ្ឋបាលកណ្តាល និងតាមខេត្ត-ក្រុង ។

## ជំពូកទី ៩

## អវសានប្បញ្ញត្តិ

មាត្រា ១៨._ រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

មាត្រា ១៩._ នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យ នេះចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០០
ក្នុងព្រះបរមនាម និង តាមព្រះរាជបញ្ជាសព្វព្រះរាជហឫទ័យ
ប្រមុខរដ្ឋស្តីទី
ហត្ថលេខា
**ជា ស៊ីម**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
ព្រះមហាក្សត្រ សូមឡាយព្រះហស្តលេខា
រាជធានីភ្នំពេញ,ថ្ងៃ ខែ ឆ្នាំ២០០០
នាយករដ្ឋមន្ត្រី
ហត្ថលេខា
**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូនសម្តេច
នាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា
រាជធានីភ្នំពេញ, ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០០
សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
ហត្ថលេខា
**ស ខេង យូ ហុកគ្រី**

★★★

# II- រាជរដ្ឋាភិបាល

## ១- អនុក្រឹត្យ

### អនុក្រឹត្យលេខ ៦៩ អនក្រ.តត
### ស្តីពីការជូនមេដាយការងារ

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/៩៤/០២ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់មេបញ្ជាការកងឯកភាពអង្គរក្សសម្តេច ហ៊ុន សែន

**សំរេច**

**មាត្រា ១ _** ត្រូវបានប្រគល់ មេដាយការងារ តាមលំដាប់ថ្នាក់ជូននាយទាហាន នាយទាហានរង និងពលទាហាន ១៧៤ រូប ដែលកងឯកភាពអង្គរក្សសម្តេចនាយករដ្ឋមន្ត្រី និងអង្គភាពសម្ព័ន្ធមេត្រីភាព ដែលមានស្នាដៃល្អឆ្នើមក្នុងការបំពេញភារកិច្ចជូនជាតិមាតុភូមិ ដូចមានរាយនាមខាងក្រោម ៖

**ក)- មេដាយមាសការងារ ចំនួន ៣៣ រូប :**

| | | | |
|---|---|---|---|
| ១-លោកឧត្តមសេនីយ៍ត្រី | ខឹម ជាសាខឿន | ៩-លោក - | ស៊ុន សុផល |
| ២-លោក - | ចិន រ៉ា | ១០-លោក - | សុខ សាឆេត |
| ៣-លោក - | ឆេព សំអាន | ១១-លោក - | សូ ណារ៉ា |
| ៤-លោក - | សែស ឧត្យសត្ថា | ១២-លោក - | ផាន់ និរន្ទ |
| ៥-លោកឧត្តមនាវីត្រី | អ៊ុក សីហា | ១៣-លោក - | ម៉ាញ យារិន្ទ |
| ៦-លោកឧត្តមសេនីយ៍ត្រី | គង់ មុនី | ១៤-លោក - | ឆេ ខា |
| ៧-លោក - | សោម សាខុំម | ១៥-លោកវរៈសេនីយ៍ឯក | លឹម លាងសែ |
| ៨-លោកវរៈសេនីយ៍ឯក | ហេង ចាន់ថា | ១៦-លោក - | ឈឹម រស្មីជា |

| | | | | | |
|---|---|---|---|---|---|
| ១៧-លោក | - | ហ៊ុន ស៊ីថា | ២៦-លោក | - | ពូន សានិត |
| ១៨-លោកវរៈសេនីយ៍ទោ | | ច្រាយ សុន | ២៧-លោក | - | ឈឿង សុខុម |
| ១៩-លោក | - | ជួន ឡឿន | ២៨-លោក | - | សំ ជិត |
| ២០-លោក | - | អ៊ួន គន្ធ | ២៩-លោក | - | រស់ សារិន |
| ២១-លោក | - | ឃួន សាមិត្ត | ៣០-លោក | - | សៀង ចាន់ |
| ២២-លោក | - | ជិន ណារ្គី | ៣១-លោក | - | រស់ ឡៀត |
| ២៣-លោក | - | ព្រាប ពិជ័យ | ៣២-លោក | - | ម៉ម សុខា |
| ២៤-លោក | - | សួន ស៊ុំា | ៣៣-លោក | - | ឆាយ នី |
| ២៥-លោកវរៈសេនីយ៍ទោ | | ស៊ិម គង់ | | | |

ខ)- <u>មេដាយប្រាក់ ចំនួន ៣៥ រូប</u> :

| | | | | | |
|---|---|---|---|---|---|
| ១-លោកវរៈសេនីយ៍ទោ | | តាក់ គន្ធុល | ១៩-លោកវរៈសេនីយ៍ត្រី | | យី នឹម |
| ២-លោក | - | ហ៊ឹម ណារិន | ២០-លោក | - | ហូ វ៉ាន់ |
| ៣-លោក | - | គឹម សាឃួន | ២១-លោក | - | សឹង សានឿន |
| ៤-លោក | - | ស្តួច សារី | ២២-លោក | - | ចាន់ ណារិទ្ធ |
| ៥-លោក | - | នាង សារិត | ២៣-លោក | - | ឡេង គឿន |
| ៦-លោក | - | ហ៊ឹង ពុធដារ៉ា | ២៤-លោក | - | ចាន់ សុផល |
| ៧-លោក | - | ឃួន ប៊ូរិន | ២៥-លោក | - | ចាន់ ប៊ុនខេង |
| ៨-លោក | - | ឡុង គឹម | ២៦-លោក | - | អ៊ុន ពៅ |
| ៩-លោក | - | ចាន់ ប៊ុនខេង | ២៧-លោក | - | គឹម តិច |
| ១០-លោក | - | អ៊ុន ពៅ | ២៨-លោក | - | នូ ណាទណ្ឌដា |
| ១១-លោក | - | អ៊ឹង សំអាត | ២៩-លោក | - | កែវ អេង |
| ១២-លោក | - | ពេជ្រ សារិទ្ធ | ៣០-លោក | - | សៀម ឆាត |
| ១៣-លោក | - | តាត សាវ៉ុន | ៣១-លោកអនុសេនីយ៍ឯក | | សុច សឿង |
| ១៤-លោកវរៈសេនីយ៍ត្រី | | ង៉ែត លៀង | ៣២-លោក | - | ម៉ៅ សុវណ្ណារិទ្ធ |
| ១៥-លោក | - | សំ ណេង | ៣៣-លោក | - | ឆេព វិត |
| ១៦-លោក | - | ផូ ម៉ុងសាន្ត | ៣៤-លោក | - | ម៉្លេង សារុត |
| ១៧-លោក | - | ម៉ាន់ ម៉ារ៉ាឌី | ៣៥-លោក | - | ហ៊ូ ឃុនអេង |
| ១៨-លោក | - | អ៊ុក វណ្ណា | | | |

គ)- មេជាយសិទ្ធ ចំនួន ១០៦ រូប :

| | | | |
|---|---|---|---|
| ១-លោកអនុសេនីយ៍ឯក | ប្រាក់ ចាន់ផល្លី | ៣០-លោកនាយចំណង់ | ឡុង លុន |
| ២-លោក - | ហួ អ៊ិត | ៣១-លោកព្រិន្ទបាលឯក | និត្យ វិសាល |
| ៣-លោក - | ស ប៊ុនលីម | ៣២-លោក - | សុទ្ធ ថា |
| ៤-លោក - | សូ ហឿន | ៣៣-លោក - | សូ ឌីម៉ា |
| ៥-លោក - | ឡេង ហុង | ៣៤-លោក - | យ៉ុក ទៀន |
| ៦-លោក - | ខូន ម៉េង | ៣៥-លោក - | ហ៊ុន គឹមអុល |
| ៧-លោកអនុសេនីយ៍ទោ | មៀន ចំរើន | ៣៦-លោក - | ហម លី |
| ៨-លោក - | នាង ត្វី | ៣៧-លោក - | សោម សាន្ត |
| ៩-លោក - | ជា សាវុធ | ៣៨-លោក - | ស៊ុំ សុផុន |
| ១០-លោក - | គិន ចំណាន | ៣៩-លោក - | ឌឹម សារ៉េត |
| ១១-លោក - | យ៉ង់ សំអុល | ៤០-លោក - | សយ គង់ |
| ១២-លោកអនុសេនីយ៍ត្រី | លឹម សាគឿន | ៤១-លោកពលបាលឯក | កៅ វ៉េត |
| ១៣-លោក - | ខាត់ សុតី | ៤២-លោក - | ជួន ម៉ុល |
| ១៤-លោក - | សៀង សេង | ៤៣-លោក - | វ័ន្ត ប៊ុនថុន |
| ១៥-លោក - | គឹម រតនា | ៤៤-លោក - | ឈុន ស៊ីឡេ |
| ១៦-លោក - | ប៊ុន ឈឿន | ៤៥-លោក - | ស៊ិន សុវណ្ណារ៉ា |
| ១៧-លោក - | ម៉ៅ ប៊ុណ្ណាត | ៤៦-លោក - | ជិន ម៉ាណាន់ |
| ១៨-លោក - | ភង សារ៉ាក់ | ៤៧-លោក - | សួន សំអាត |
| ១៩-លោក - | សុទ្ធ តាព | ៤៨-លោក - | នួន សារ៉ុម |
| ២០-លោក - | ជា សុធា | ៤៩-លោក - | ហ៊ាន សេងហ៊ាន |
| ២១-លោក - | ហួត ឆា | ៥០-លោក - | សំ សាមឿន |
| ២២-លោក - | សូ ឡេត | ៥១-លោក - | ង៉ែ ប៊ុនជឿន |
| ២៣-លោកអនុសេនីយ៍ឯក | សំ សំអុល | ៥២-លោក - | រ៉ុន សម័យ |
| ២៤-លោក - | សុខ ហេង | ៥៣-លោក - | ចិន សុគន្ធ |
| ២៥-លោក - | ណុប ម៉ីសុខុន | ៥៤-លោក - | យ៉ន ម៉ន |
| ២៦-លោក - | ឡាំ ប៊ុនលុច្ស | ៥៥-លោក - | យ៉ុម ចិត្រា |
| ២៧-លោក - | ឡុង ប៉ាក់ | ៥៦-លោក - | កែវ ចំរើន |
| ២៨-លោកនាយចំណង់ | មុត ប៊ូរី | ៥៧-លោក - | ស៊ឹង សាត |
| ២៩-លោក - | ឡុង លិន | ៥៨-លោក - | ហៀង តារ៉ា |

៥៩-លោកពលបាលឯក គង់ សម្ផស្ស
៦០-លោក - ភួច ឡេង
៦១-លោក - ឌុច ជន
៦២-លោក - ដួង សាវិន
៦៣-លោក - ម៉ុន វុទ្ធី
៦៤-លោក - ឡាំ ផុង
៦៥-លោក - សេ សុផល
៦៦-លោក - ម៉ូច ជឿន
៦៧-លោក - ឌុយ នឹម
៦៨-លោក - នឹង ប៊ុណ្ណ
៦៩-លោក - ហុន តារម្យ
៧០-លោក - តាក់ សារ៉ែន
៧១-លោក - លឹម តារុណ
៧២-លោក - នាង រិត
៧៣-លោក - យ៉ាន ឡុង
៧៤-លោក - សេក សំអាត
៧៥-លោក - ហង្ស សម្ផស្ស
៧៦-លោក - ភួយ ពិសិដ្ឋ
៧៧-លោក - ស៊ិន សាវ័ន្ត
៧៨-លោក - ហ៊ុន ហឿន
៧៩-លោក - សៅ សំណាង
៨០-លោក - តេង សុខា
៨១-លោក - ជុន តារា
៨២-លោក - នង ចំណាន
៨៣-លោក ពលទោ កែវ សុផាណា
៨៤-លោក - ជា ស៊ីណុន
៨៥-លោក - គួង ចន្ថា
៨៦-លោក - ប្រាក់ វុទ្ធី
៨៧-លោក - កែ សុតា
៨៨-លោក - ស៊ុល សុខសាវតា
៨៩-លោក - មុត សាមឿន
៩០-លោក - ឆាយ សុវណ្ណ
៩១-លោក - អោក សំអាត
៩២-លោក - រ៉ុន សក្កា
៩៣-លោក - ជឿន រ័ត្ន
៩៤-លោក - ឌូច សារ៉ាវុធ
៩៥-លោក - ថា ធា
៩៦-លោក - អៀន ម៉ុនធី
៩៧-លោក - សេក សម្បត្តិ
៩៨-លោក - ចាន់ ពិសិដ្ឋ
៩៩-លោក - ជិន មុន្នី
១០០-លោក - កើត សាម៉ុន
១០១-លោក - អ៊ឹម ចំរើន
១០២-លោក - ផង់ ប៊ុននាង
១០៣-លោក - វី ម៉ឺង
១០៤-លោក - ស៊ុំ វាសនា
១០៥-លោក - កែម ណារ៉ាន់
១០៦-លោក - ម៉ៅ វណ្ណស៊ី

***

**មាត្រា ២.**_ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអេបញ្ញាការកងឯកភាពអង្គរក្ស សម្តេច ហ៊ុន សែន ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធផលចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យលេខ ៧០ អនក្រ.តត
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/៩៤/០២ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល

## សំរេច

**មាត្រា ១ .**_ ត្រូវបានប្រគល់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក JOE WHITE និងគ្រួសារសញ្ជាតិអាមេរិកាំង ដែលបានជួយសាងសង់អាគារព្យាបាលថ្មីមួយខ្នង ជូនមន្ទីរពេទ្យកុមារជាតិ តាមរយៈអង្គការទស្សនៈពិភពលោកអន្តរជាតិ ចំណាយអស់ថវិកាសរុប ២៧៣.១១៩,៥៨ ដុល្លារអាមេរិក ។

**មាត្រា ២ .**_ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងសុខាភិបាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធផលចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

# អនុក្រឹត្យលេខ ៧១ អនក្រ.តត
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/៩៤/០២ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសឱ្យប្រើគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកអភិបាលរាជធានីភ្នំពេញ

**សំរេច**

មាត្រា ១ .- ត្រូវបានប្រគល់ មេដាយមាសស្ថាបនាជាតិ ជូនសប្បុរសជន ដែលបានបរិច្ចាគថវិកា ជួយកសាងសង់អាគារសិក្សាមួយខ្នង កំពស់ ០៤ ជាន់ មាន ៣៥ បន្ទប់ នៅសាលាបឋមសិក្សា ពោធិ៍ ដោះគ្រះគក តំលៃសរុបថវិកា ចំនួន ៥៩៥.០០០ ដុល្លារអាមេរិក ដូចមានរាយនាមខាងក្រោមនេះ ៖

១- សអោគម ចិន ហុកគៀន

២- លោក ហុក ស្រ៊ីនខៀវ រស់នៅសហរដ្ឋអាមេរិក

មាត្រា ២ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកអភិបាលរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

# អនុក្រឹត្យលេខ ៧២ អនក្រ.តត
# ស្តីពីការតែងតាំងមន្ត្រីរាជការ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/៩៤/០២ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ NS/KRT-34 ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងព្រះបរមរាជវាំង
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង

## សំរេច

**មាត្រា ១ .-** ត្រូវបានតែងតាំងមន្ត្រីរាជការ នៃក្រសួងព្រះបរមរាជវាំង ដូចមានរាយនាមខាងក្រោម ៖

១- លោក មូល សារឿន ជា ប្រធាននាយកដ្ឋាន រដ្ឋបាល
២- លោក នូ ឌុម ជា ប្រធាននាយកដ្ឋាន ផែនការ-គណនេយ្យ
៣- លោក សូ ស៊ីនួន ជា ប្រធាននាយកដ្ឋាន ដឹកជញ្ជូន
៤- លោក ណិម ចាន់ស្មើ ជា ប្រធាននាយកដ្ឋាន គ្រប់គ្រងព្រះរាជតំណាក់
៥- លោក ហាស អ៊ីន ជា ប្រធាននាយកដ្ឋាន ឧបត្ថម្ភ និងសង្គ្រោះប្រជារាស្ត្រ
៦- លោក យូ ស៊ីអ៊ែល ជា ប្រធាននាយកដ្ឋាន អភិរក្ស

**មាត្រា ២ .-** បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

# អនុក្រឹត្យលេខ ៧៣ អនក្រ.តត
# ស្តីពីការតែងតាំងមន្ត្រីរាជការ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០៧/អនក្រ.បក. ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងពត៌មាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពត៌មាន

## សំរេច

**មាត្រា ១ .–** ត្រូវបានតែងតាំងលោក ខួន សុផល ជាអធិការនៃអធិការដ្ឋានក្រសួងពត៌មាន មានឋានៈស្មើប្រធាន នាយកដ្ឋាន ។

**មាត្រា ២ .–** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពត៌មាន រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

# អនុក្រឹត្យលេខ ៧៥ អនក្រ.តត
# ស្តីពីការតែងតាំងមន្ត្រីរាជការ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងពត៌មាន
- យោងតាមសំណើរបស់ក្រសួងពត៌មាន

## សំរេច

មាត្រា ១ .- ត្រូវបានតែងតាំងលោក **លាវ ស៊ីណារ៉ា** ជាប្រធាននាយកដ្ឋានឯកសារ បណ្ណាល័យ នៃអគ្គនាយកដ្ឋាន ទីភ្នាក់ងារសារពត៌មានកម្ពុជា (AKP) នៃក្រសួងពត៌មាន ។

មាត្រា ២ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពត៌មាន រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

***

# អនុក្រឹត្យលេខ ៧៥ អនក្រ.តត
# ស្តីពីការតែងតាំងមន្ត្រីរាជការ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងពត៌មាន
- យោងតាមសំណើរបស់ក្រសួងពត៌មាន

## សំរេច

មាត្រា ១ .- ត្រូវបានតែងតាំងលោក គាត ទណ្ណៈ ជាប្រធាននាយកដ្ឋានពត៌មាននៃក្រសួងពត៌មាន ។

មាត្រា ២ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពត៌មាន រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

# អនុក្រឹត្យលេខ ៧៦ អនក្រ.តត
# ស្តីពីការបញ្ឈប់ និងដកហូតតំណែងអភិបាលរងខេត្ត-ក្រុង

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/៩៤/០២ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សំរេច**

**មាត្រា ១ .-** ត្រូវបានបញ្ឈប់ និងដកហូតមុខតំណែងលោក មាស ឌន ពីអភិបាលរងទី១ ខេត្តមណ្ឌលគិរី ហើយបញ្ជូនទៅក្នុងក្របខ័ណ្ឌ នៃក្រសួងការពារជាតិវិញ ។

**មាត្រា ២ .-** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ប្រតិភូរាជរដ្ឋាភិបាលអភិបាលខេត្ត-ក្រុង ដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យលេខ ៧៧ អនក្រ.តត

## ស្តីពីការតែងតាំងអភិបាលរង ខេត្ត-ក្រុង

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/៩៤/០២ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សំរេច**

មាត្រា ១ .- ត្រូវបានតែងតាំងលោក ខូយ ឃុនហួរ ជាអភិបាលរងទី១ ខេត្តមណ្ឌលគិរី ។

មាត្រា ២.- បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ប្រតិភូរាជរដ្ឋាភិបាល អភិបាលខេត្ត-ក្រុង ដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

**អនុក្រឹត្យលេខ ៧៨ អនក្រ.តត**

**ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ**

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/រកម/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសអោយប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់ អភិបាលខេត្តកំពត

សំរេច

**មាត្រា ១ .-** ត្រូវបានប្រគល់ **មេដាយធិបឌិន្ទមុនីសារាភ័ណ្ឌ** ជូនលោកស្រី MARIKO OKAMURA ប្រធានអង្គការ ASAC "ជប៉ុន" ដែលមានស្នាដៃល្អ និងគុណបំណាច់ខ្ពស់ ក្នុងការជួយកសាង និងអភិវឌ្ឍន៍ វិស័យអប់រំ នៅព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា និងអភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យលេខ ៧៩ អនក្រ.តត

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/រកម/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសអោយប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់ អភិបាលខេត្តកំពត

## សំរេច

**មាត្រា ១ .-** ត្រូវបានប្រគល់ មេដាយមាសស្ថាបនាជាតិ ជូនសប្បុរសជន ជប៉ុន ដែលបានបរិច្ចាគធនធានជួយកសាងអាគារសិក្សានៅសាលាបឋមសិក្សា ក្នុងស្រុកកំពត ចំណាយអស់ថវិកាសរុបចំនួន ៣៩៥.៩០០ USD ដូចមានរាយនាមខាងក្រោមនេះ ៖

១- ស្ថានឯកអគ្គរាជទូតជប៉ុន ប្រចាំនៅកម្ពុជា
២- សមាជិកពកម្មករ អាជីណូម៉ូតូ
៣- សប្បុរសជន នីគ្រូខណូដា
៤- លោកតា គូមូតា
៥- លោក មីយ៉ាម៉ា

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា និងអភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០០
នាយករដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
ហ៊ុន សែន

★★★

# អនុក្រឹត្យលេខ ៨០ អនក្រ.តត
# ស្តីពីការជូនមេដាយការងារ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/រកម/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសអោយប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

- យោងតាមសំណើរបស់ អភិបាលខេត្តកំពត

**សំរេច**

មាត្រា ១ .- ត្រូវបានប្រគល់ មេដាយប្រាក់ការងារ ជូនមន្ត្រី ០៥ រូប ដែលមានស្នាដៃល្អ ក្នុងការចូលរួមសហការកសាងសាលារៀន នៅក្នុងស្រុកកំពត ខេត្តកំពត ដូចមានរាយនាមខាងក្រោម ៖

១- លោក ឃុយ សៀន អភិបាលស្រុកកំពត

២- លោក ស៊ុម ទុន្ធា អភិបាលរងស្រុកកំពត

៣- លោក សៅ សំបូរ អភិបាលរងស្រុកកំពត

៤- លោក ម៉ៅ យ៉ន អភិបាលរងស្រុកកំពត

៥- លោក តូច នេត ប្រធានការិយាល័យអប់រំ យុវជន និងកីឡា ស្រុកកំពត

មាត្រា ២ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០០

នាយករដ្ឋមន្ត្រី

បាត្តលេខា និងត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យលេខ ៨១ អនក្រ.តត
## ស្តីពីការជូនមេដាយការងារ

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/រកម/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសអោយប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

- យោងតាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សំរេច**

មាត្រា ១ .- ត្រូវបានប្រគល់ មេដាយការងារ តាមលំដាប់ថ្នាក់ជូនអតីតអភិបាល អភិបាលរងស្រុក ខ័ណ្ឌ ចំនួន ៤២ រូប ដែលបានខិតខំ ប្រឹងប្រែងគ្រប់ឧបសគ្គក្នុងការដឹកនាំរៀបចំ ស្រុក-ខ័ណ្ឌ សំរេចបានសមិទ្ធផលជាច្រើន រួមចំណែកស្តារ និងអភិវឌ្ឍន៍ មាតុភូមិកម្ពុជា ហើយដែលបានដាក់ អោយចូលនិវត្តន៍ ដូចមានរាយនាមខាងក្រោម ៖

ក- មេដាយមាសការងារ

១- លោក ពេញ សឿន អភិបាលស្រុកពញាឮ ខេត្តកណ្តាល

២- លោក ហ៊ិន សុន អភិបាលស្រុកលើកដែក ខេត្តកណ្តាល

៣- លោក ជ៉ាន់ ឈីម អភិបាលស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម

៤- លោក ញឹក ឆឿន អភិបាលស្រុកបរិបូណ៍ ខេត្តកំពង់ឆ្នាំង

៥- លោក សែម ឃុត អភិបាលស្រុកគូលែន ខេត្តព្រះវិហារ

៦- លោក ស៊ិន អ អភិបាលស្រុកសេរីសោភ័ណ្ឌ ខេត្តបន្ទាយមានជ័យ

៧- លោក លិសរី អភិបាលខ័ណ្ឌចំការមន ក្រុងភ្នំពេញ

៨- លោក កែវ សារ៉េត អភិបាលស្រុកមេសាង ខេត្តព្រៃវែង

៩- លោក គន់ គីមឃុន អភិបាលស្រុកពារាំង ខេត្តព្រៃវែង

១០-លោក មាស មាន់ អភិបាលខ័ណ្ឌស្ទឹងហាវ ក្រុងព្រះសីហនុ

១១-លោក មាស សាផន អភិបាលស្រុក កំពង់ត្រាច ខេត្តកំពត

១២-លោក ឈុន ស៊ីនួន អភិបាលស្រុក ប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ

១៣-លោក ប្រាក់ គិន អភិបាលស្រុក ស្វាយជ្រុំ ខេត្តស្វាយរៀង

១៤-លោក កែ ជុំ អភិបាលស្រុក ជីក្រែង ខេត្តសៀមរាប

១៥-លោក លួន ទ៉ាន់ឌី អភិបាលស្រុក សៀមប៉ាង ខេត្តស្ទឹងត្រែង

១៦-លោក ឡេន ណើយ អភិបាលស្រុក បរកែវ ខេត្តរតនគិរី

ខ- មេដាយប្រាក់ការងារ

១- លោក មៀច ហេង អភិបាលរងស្រុក ព្រែកប្រសព្វ ខេត្តក្រចេះ

២- លោក ឡើង ចន្ថា អភិបាលរងស្រុក ស្វាយចេក ខេត្តបន្ទាយមានជ័យ

៣- លោក សុខ ម៉ុន អភិបាលរងស្រុក អូរជ្រៅ ខេត្តបន្ទាយមានជ័យ

៤- លោក អ៊ុក សំអុន អភិបាលរងស្រុក ល្វាឯម ខេត្តកណ្តាល

៥- លោក ឈិ សារុន អភិបាលរងស្រុក រំដួល ខេត្តស្វាយរៀង

៦- លោក អ៊ុក ឆាន អភិបាលរងស្រុក រមាសហែក ខេត្តស្វាយរៀង

៧- លោក ប្រាក់ សំអែល អភិបាលរងស្រុក កំពង់លែង ខេត្តកំពង់ឆ្នាំង

៨- លោក ចន្ទ មិច អភិបាលរងស្រុក កំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង

៩- លោក ស៊ឹម សុខហេង អភិបាលរងខណ្ឌ ព្រៃនប់ ក្រុងព្រះសីហនុ

១០- លោក ទឹម ចាន អភិបាលរងខណ្ឌ មានជ័យ ក្រុងភ្នំពេញ

១១- លោក ស៊ូ ឈុន អភិបាលរងខណ្ឌ ឫស្សីកែវ ក្រុងភ្នំពេញ

១២- លោក អ៊ុន ហ៊ុន អភិបាលរងខណ្ឌ មានជ័យ ក្រុងភ្នំពេញ

១៣- លោក ឌុក យោ អភិបាលរងស្រុក អង្គរជ័យ ខេត្តកំពត

១៤- លោក ខឹម ឈុំ អភិបាលរងស្រុក មេសាង ខេត្តព្រៃវែង

១៥- លោក កុយ យន់ អភិបាលរងស្រុក កំពង់ត្រាច ខេត្តកំពត

១៦- លោក អ៊ុច ស៊ិន អភិបាលរងស្រុក កំពង់ស្វាយ ខេត្តកំពង់ធំ

១៧- លោក ញ៉ឹម ប៊ុន អភិបាលរងស្រុក ប្រាសាទបល្ល័ង្ក ខេត្តកំពង់ធំ

១៨- លោកស្រី អ៊ុក ថៃខោរ អភិបាលរងស្រុក បារាយណ៍ ខេត្តកំពង់ធំ

១៩- លោក ស្រី ប៊ូ អភិបាលរងស្រុក ប្រាសាទបាគង ខេត្តសៀមរាប

២០- លោក ប៊ុន់ ឡា អភិបាលរងស្រុក ស្ទឹងត្រែង ខេត្តស្ទឹងត្រែង

២១- លោក ហួន ទើ អភិបាលរងស្រុក ស្ទឹងត្រែង ខេត្តស្ទឹងត្រែង

២២- លោក រចំ ឡៃ អភិបាលរងស្រុក បរកែវ ខេត្តរតនគិរី

២៣- លោក ញ៉ឹន នៃស៊ី អភិបាលរងស្រុក បានលុង ខេត្តរតនគិរី

២៤- លោក អ៊ិច រិន អភិបាលរងស្រុក ក្រូចឆ្មារ ខេត្តកំពង់ចាម

២៥- លោក ឡុញ សន អភិបាលរងស្រុក កោះសូទិន ខេត្តកំពង់ចាម

២៦- លោក នួន សាខិម អភិបាលរងស្រុក អង្គរបុរី ខេត្តតាកែវ

មាត្រា ២.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

## ២- សេចក្ដីសំរេច

រាជធានីភ្នំពេញ, ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០០

សេចក្ដីសំរេចលេខ ១៣ សសរ.

ស្ដីពីការផ្ទេរសិទ្ធិ នៃរាជរដ្ឋាភិបាល

***

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា

សំរេច

ប្រការ ១.- ផ្ទេរសិទ្ធិជូនឯកឧត្ដម ស ខេង ឧបនាយករដ្ឋមន្ត្រី និងជាសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជានាយករដ្ឋមន្ត្រីស្ដីទី នៃរាជរដ្ឋាភិបាលកម្ពុជា ជំនួសសម្ដេចនាយរដ្ឋមន្ត្រី ដែលត្រូវអញ្ជើញទៅធ្វើទស្សនកិច្ចជាផ្លូវការនៅសាធារណរដ្ឋឥណ្ឌា និងអញ្ជើញទៅធ្វើទស្សនកិច្ចជាផ្លូវការ នៅសហភាព មីយ៉ាន់ម៉ា ចាប់ពីថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០០ រហូតដល់សម្ដេចនាយករដ្ឋមន្ត្រី អញ្ជើញវិលត្រឡប់មកកាន់មាតុប្រទេសវិញ ។

ប្រការ ២.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួង-ស្ថាប័ន ប្រតិភូរាជរដ្ឋាភិបាល អភិបាលគ្រប់ខេត្ត-ក្រុង និងឯកឧត្ដម ស ខេង ត្រូវអនុវត្តសេចក្ដីសំរេចឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

***

# III- ការងារបណ្ដាក្រសួង

## ១- ធនាគារជាតិនៃកម្ពុជា

## ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០០

**ប្រកាសលេខ ធ ៧០០-៤៦ ប្រក.**

**ស្ដីពីអនុបាតសាធនភាពរបស់ធនាគារ**

***

**ទេសាភិបាល ធនាគារជាតិនៃកម្ពុជា**

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣៩៨/៨៥ ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ១៩៩៨ ស្ដីពី ការតែងតាំង ឯកឧត្ដម **ជា ចាន់តូ** ជាអគ្គទេសាភិបាលនៃធនាគារជាតិនៃកម្ពុជា
- យោងតាមសំណើរបស់នាយកដ្ឋានត្រួតពិនិត្យ

**សំរេច**

**ប្រការ ១ :**

ធនាគារទាំងអស់ត្រូវពិនិត្យជាអចិន្ត្រៃយ៍ នូវអនុបាតសាធនភាពរបស់ខ្លួនអោយបានស្រប តាមបញ្ញត្តិនៃប្រកាសនេះ ។ អនុបាតសាធនភាពរវាងមូលនិធិផ្ទាល់សុទ្ធនិងហានិភ័យឥណទាន សរុប មិនត្រូវតិចជាងម្ភៃភាគរយ (២០%) ឡើយ ។

**ប្រការ ២ :**

ភាគយកនៃអនុបាត គឺជាមូលនិធិផ្ទាល់សុទ្ធដែលត្រូវបានគណនាស្របតាមបញ្ញត្តិនៃ ប្រកាសស្ដីពីការគណនាមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ ។

**ប្រការ ៣ :**

៣-១- ភាគបែងនៃអនុបាត គឺជាតំលៃទ្រព្យសកម្មសរុប (តំលៃសុទ្ធក្រោយពេលដក ចេញនូវសំវិធានធននិងការរំលោះតំលៃ) និងខ្ទង់ក្រៅតារាងតុល្យការដែលត្រូវបានថ្លឹងតាមកំរិត

ហានិភ័យឥណទាន ។ ភាគរយនេះមិនរាប់បញ្ចូលនូវខ្ទង់ដែលបានដកចេញ នៅ ពេលគណនាមូលនិធិផ្ទាល់សុទ្ធ ស្របតាមបញ្ញត្តិនៃប្រកាសស្តីពីការគណនាមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ ។

៣-២- ការថ្លឹងដូចខាងក្រោមនេះ នឹងអនុវត្តចំពោះទ្រព្យសកម្ម ៖

៣-២-១- ការថ្លឹងសូន្យភាគរយ (zero weighting) ចំពោះ ៖

- សាច់ប្រាក់
- មាស
- ឥណទេយ្យលើធនាគារជាតិនៃកម្ពុជា
- ទ្រព្យសកម្មដែលបានធានាដោយប្រាក់បញ្ញើនៅធនាគារដដែល
- ឥណទេយ្យលើស្ថាប័នអធិបតេយ្យ (Claims on sovereigns) ដែលមានចំណាត់ថ្នាក់ពី AAA ទៅ AA- តាមវិធីសាស្ត្ររបស់ Standard and Poor's Corporation ។

៣-២-២- ការថ្លឹង ២០% ចំពោះ ៖

- ឥណទេយ្យលើស្ថាប័នអធិបតេយ្យ ដែលមានចំណាត់ថ្នាក់ពី A+ ទៅ A- តាមវិធីសាស្ត្ររបស់ Standard and Poor's Corporation
- ឥណទេយ្យលើធនាគារ ដែលមានចំណាត់ថ្នាក់ពី AAA ទៅ AA- តាមវិធីសាស្ត្ររបស់ Standard and Poor's Corporation ។

៣-២-៣- ការថ្លឹង ៥០% ចំពោះ ៖

- ឥណទេយ្យលើស្ថាប័នអធិបតេយ្យ ដែលមានចំណាត់ថ្នាក់ពី BBB+ ទៅ BBB- តាមវិធីសាស្ត្ររបស់ Standard and Poor's Corporation
- ឥណទេយ្យលើធនាគារ ដែលមានចំណាត់ថ្នាក់ពី A+ ទៅ A- តាមវិធីសាស្ត្ររបស់ Standard and Poor's Corporation ។

៣-២-៤- ការថ្លឹង ១០០% ចំពោះ

- ទ្រព្យសកម្មដទៃទៀតទាំងអស់ ។

៣-៣- បញ្ញត្តិដូចតទៅនេះ នឹងត្រូវអនុវត្តចំពោះខ្ទង់ក្រៅតារាងតុល្យការ ៖

៣-៣-១- ខ្ទង់ក្រៅតារាងតុល្យការត្រូវបានចាត់ថ្នាក់ជា ៤ ប្រភេទ ស្របតាមតារាងដែលមានក្នុងឧបសម្ព័ន្ធ ។ ខ្ទង់ក្រៅតារាងតុល្យការទាំងនេះត្រូវបានយកមកគិត

- តាមតំលៃទាំងស្រុងរបស់វា នៅពេលបានចាត់ថ្នាក់ជាមានហានិភ័យទាំងស្រុង
- តាមតំលៃ ៥០% នៅពេលបានចាត់ថ្នាក់ជាមានហានិភ័យកំរិតមធ្យម

- យ៉ាងតិចបំផុត ២០% នៅពេលបានចាត់ថ្នាក់ថាមានហានិភ័យធុនល្មម (Moderate risk)
- ខ្ទង់ដែលត្រូវបានចាត់ថ្នាក់ថាមានហានិភ័យទាបមិនត្រូវបានយកមកគិតទេ ។

៣-៣-២- ចំនួនប្រាក់ដែលបានកំណត់ខាងលើ ត្រូវគុណជាមួយនឹងប្រភេទថ្លឹង ដែលមានចែងនៅក្នុងកថាខណ្ឌ ៣-២ ដែលត្រូវអនុវត្តចំពោះប្រភេទនៃការថ្លឹង របស់អត្ថគាហកៈ ឬប្រភេទទ្រព្យសកម្មពាក់ព័ន្ធនោះ ។ ប៉ុន្តែ ៖

- ក្នុងករណីនៃការសន្យាដែលមានការធានាពីតតិយជន ការថ្លឹងគឺជាការថ្លឹងដែលអនុវត្តចំពោះអ្នកធានា ឬចំពោះអ្នកដែលត្រូវបានគេធានា
- ក្នុងករណីនៃការធានាចំពោះធនាគារមួយផ្សេងទៀតទាក់ទងជាមួយការសងប័ណ្ណដែលរក្សាទុកនៅធនាគារផ្សេងទៀតនោះ ការថ្លឹងជាការថ្លឹងដែលអនុវត្តចំពោះធនាគារទៀតនេះ ។

ប្រការ ៤ :

ធនាគារត្រូវប្រតិវេទអនុបាតសាធនភាពរបស់ខ្លួននៅ ថ្ងៃទី៣០ ខែមិថុនា និង ថ្ងៃទី៣១ ខែធ្នូជារៀងរាល់ឆ្នាំ ។ លើសពីនេះ ធនាគារជាតិនៃកម្ពុជានឹងអាចតម្រូវអោយធនាគារណាមួយគណនាអនុបាតសាធនភាពរបស់ខ្លួន នៅកាលបរិច្ឆេទផ្សេងទៀត ស្របតាមការចាំបាច់នៃការត្រួតពិនិត្យ ។

ធនាគារជាតិនៃកម្ពុជាត្រូវកំណត់ក្នុងសារាចរ ពីទំរង់រាប់គណនាអនុបាត ដោយត្រូវប្រកាសពីខ្ទង់ទាំងឡាយក្នុងទំរង់នេះ ។

ប្រសិនបើចាំបាច់ ធនាគារជាតិនៃកម្ពុជាត្រូវកំណត់ច្បាស់អំពីលក្ខណៈពិសេសរបស់ខ្ទង់ដែលត្រូវអនុវត្តការថ្លឹង ដូចមានចែងក្នុងប្រការ ៣ នៃប្រកាសនេះ ។

ធនាគារជាតិនៃកម្ពុជាអាចបដិសេធចំពោះការថ្លឹងដែលកំពុងអនុវត្តចំពោះទ្រព្យសកម្ម ឬខ្ទង់ក្រៅតារាងតុល្យការ ប្រសិនបើគិតថាខ្ទង់នោះមិនអាចបំពេញតាមលក្ខខណ្ឌជាធរមានបានដោយពេញចិត្តនោះទេ ។

ប្រការ ៥ :

ធនាគារជាតិនៃកម្ពុជាតម្រូវអោយមានការយកចិត្តទុកដាក់ថា គោលនយោបាយគណនេយ្យខ្សោយ ឬ មិនគ្រប់គ្រាន់ធ្វើឲ្យអន្តរាយដល់សារៈប្រយោជន៍នៃការិតដើមទុន ដោយបង្កឲ្យមានអនុបាតសាធនភាពមិនត្រឹមត្រូវ ឬមិនអាចជឿបាន ។ ដូច្នេះ ធនាគារជាតិនៃកម្ពុជាចាត់ទុកថា

ការអនុវត្តន៍គណនេយ្យរឹងមាំ និងការវាយតំលៃត្រឹមត្រូវជាការសំខាន់ ជាពិសេស ចំពោះការចាត់ថ្នាក់ត្រឹមត្រូវនិងការធ្វើសវិធានធនទ្រព្យសកម្មតាមបញ្ញត្តិនៃប្រកាសស្តីពីចំណាត់ថ្នាក់និងការធ្វើសវិធានធនលើបំណុលអាក្រក់ និងបំណុលសង្ស័យរួមទាំងការប្រាក់ដែលបានព្យួរ ។

ប្រការ ៦ :

រាល់លិខិតបទដ្ឋានទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៧ :

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គលេខា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាព និងគ្រប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ នៅក្រោមអំណាច និងក្រោមអាណាព្យាបាល ធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ។

ប្រការ ៨ :

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០០

ទេសាភិបាល

ហត្ថលេខា និងត្រា

ជា ចាន់តូ

★★★

**ឧបសម្ព័ន្ធនៃប្រកាសស្តីពីអនុបាតសាធនភាពរបស់ធនាគារ**
**ចំណាត់ថ្នាក់ខ្ទង់ក្រៅតារាងតុល្យការ ដែលមានចែង**
**ក្នុងកថាខណ្ឌ ៣-៣-១**

***

ប្រតិបត្តិការទាំងឡាយណាដែលមិនមានចែងក្នុងតារាងខាងក្រោមនេះ ធនាគារត្រូវចាត់ថ្នាក់ខ្ទង់ទាំងនេះក្នុងប្រភេទប្រតិបត្តិការ ដែលមានលក្ខណៈស្រដៀងគ្នា បន្ទាប់ពីបានស្នើសុំធនាគារជាតិនៃកម្ពុជា ប្រសិនបើចាំបាច់ ។

១- ប្រតិបត្តិការដែលត្រូវបានចាត់ថ្នាក់ថាមានហានិភ័យទាំងស្រុង

- ការធានាលើឥណទាន (ដកចេញហានិភ័យចំពោះអត្ថគាហកៈ)
- ការទទួលព្រម (acceptance)

- វ្ញូបិយបណ្ណ (endorsement) លើផលប័ត្រដែលមិនមានឈ្មោះរបស់ធនាគារឬគ្រឹះស្ថានហិរញ្ញវត្ថុមួយផ្សេងទៀត
- សកម្មភាពប្រតិបត្តិការដោយមានឧបាស្រ័យ (recourse)
- កំរិតឥណទានមិនអាចបដិសេធបាន (irrevocable credit line) ឬការធានា ដែលមានលក្ខណៈជំនួសឥណទាន ។
- ប្រតិបត្តិការផ្សេងទៀតដែលមានហានិភ័យខ្ពស់

២- ប្រតិបត្តិការដែលត្រូវបានចាត់ថ្នាក់ថាមានហានិភ័យមធ្យម

- ការសន្យាសងប្រាក់តាមឯកសារឥណទាន ដែលបានចេញផ្សាយឬបញ្ជាក់ហើយ នៅពេលដែលទំនិញមិនត្រូវបានប្រើជាវត្ថុបញ្ចាំ
- ការធានានិងសញ្ញាប័ណ្ណឧបត្ថម្ភ (warranties and indemnity bonds) (រួមមាន tender, performance, customs and tax bonds) និងការធានាដែលមិនមានលក្ខណៈជំនួសឥណទាន
- កិច្ចសន្យាផ្តល់ឥណទានមិនទាន់ប្រើ ជាពិសេសឥណទានលើសសមតុល្យ (overdrrafts) និងការសន្យាអោយខ្ចីដែលមានកាលកំណត់លើសពីមួយឆ្នាំ
- ប្រតិបត្តិផ្សេងទៀតដែលមានហានិភ័យមធ្យម

៣- ប្រតិបត្តិការដែលត្រូវបានចាត់ថ្នាក់ថាមានហានិភ័យធូនល្មម

- ឯកសារឥណទានដែលត្រូវបានចេញផ្សាយឬបញ្ជាក់ហើយ ទំនិញត្រូវបានប្រើជាវត្ថុបញ្ចាំនិងប្រតិបត្តិការស្រដៀងគ្នាផ្សេងទៀត
- ប្រតិបត្តិការផ្សេងទៀតដែលមានហានិភ័យធូនល្មម

៤- ប្រតិបត្តិការដែលត្រូវបានចាត់ថ្នាក់ថាមានហានិភ័យទាប

- ឥណទានមិនទាន់ប្រើប្រាស់ ជាពិសេសឥណទានលើសសមតុល្យ (overdrafts) និងការសន្យាអោយខ្ចីដែលមានកាលកំណត់របូតពេញមួយឆ្នាំ ឬដែលអាចលុបចោលដោយគ្មានល័ក្ខខ័ណ្ឌនៅពេលណាក៏បានដោយគ្មានការជូនដំណឹង ។
- ប្រតិបត្តិការផ្សេងទៀតដែលមានហានិភ័យទាប ។

★★★

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០១

## ប្រកាសលេខ ធ ៧០០-៨៧ ប្រក.
## ស្ដីពីការគណនាមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ

***

## ទេសាភិបាល ធនាគារជាតិនៃកម្ពុជា

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣៩៨/៨៥ ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ១៩៩៨ ស្ដីពី ការតែងតាំង ឯកឧត្ដម **ជា ចាន់តូ** ជាអគ្គទេសាភិបាលនៃធនាគារជាតិនៃកម្ពុជា
- យោងតាមសំណើរបស់នាយកដ្ឋានត្រួតពិនិត្យ

## សំរេច

**ប្រការ ១ :**

មូលនិធិផ្ទាល់សុទ្ធរបស់ធនាគារត្រូវបានគណនាដូចតទៅ ៖

I- សរុប A ខ្ទង់ត្រូវបូក

- ដើមទុន ឬមាគ្គទ្ទេសដើមទុន
- មូលប្បទានព្រោះពីទុនបំរុងពីការវាយតំលៃឡើងវិញ
- បុព្វលាភទាក់ទងនឹងដើមទុន (បុព្វលាភភាគហ៊ុន)
- សំវិធានធនចំពោះហានិភ័យទូទៅនៃប្រតិបត្តិការធនាគារ ដោយមានការយល់ព្រមជាមុនពីធនាគារជាតិនៃកម្ពុជា
- ចំណេញរក្សាទុកសំរាប់វិនិយោគបន្ត (retained earnings)
- ចំណេញសុទ្ធ ដែលបានផ្ទៀងផ្ទាត់ហើយរបស់រាប់ឆ្នាំហិរញ្ញវត្ថុចុងក្រោយ [១]
- ខ្ទង់ផ្សេងៗទៀត ដែលអនុញ្ញាតដោយធនាគារជាតិនៃកម្ពុជា [២] ។

II- សរុប B ខ្ទង់ត្រូវដក

- ចំពោះភាគទុនិកៈ នាយក នាយកចាត់ការ និងសម្ព័ន្ធញាតិ
  - ចំណែកដើមទុនដែលមិនទាន់បានបង់
  - បុរេប្រទាននិងឥណទាន
  - ឧបករណ៍ដែលមានពត្តលេខាជនពាក់ព័ន្ធ
- ការកាន់កាប់ភាគហ៊ុនផ្ទាល់ ដែលបានវាយតំលៃតាមតំលៃចុះបញ្ជី
- ការខាតបង្គរ
- ស្រួស្រេកម្មអរូបីយ៍ រួមបញ្ចូលទាំងចំណាយក្នុងការផ្តើមបង្កើត
- ការខាតដែលកំណត់តាមគ្រាក្រៅពីការខាតនាចុងការិយបរិច្ឆេទគណនេយ្យប្រចាំឆ្នាំបញ្ចូលទាំងសវិធានធនសំរាប់បំណុលនិងមូលប័ត្រសង្ស័យ ។

III- សរុប C មូលនិធិផ្ទាល់សុទ្ធមូលដ្ឋាន = A - B

---

(១)ក្រោយពីដកភាគលាភដែលត្រូវបែងចែក

(២)ឧទាហរណ៍ប្រាក់ចំណេញដែលបានកត់ត្រាតាមគ្រាក្រៅពីប្រាក់ចំណេញនៅចុងការិយបរិច្ឆេទគណនេយ្យប្រចាំឆ្នាំ

ក្នុងល័ក្ខខ័ណ្ឌដែល ៖

- ប្រាក់ចំណេញនោះត្រូវបានកំណត់ក្រោយពេលបានចុះបញ្ជីនូវចំណាយទាំងអស់ណា ដែលទាក់ទងនឹងគ្រានោះ និងចំណាយរំលស់ព្រមទាំងសវិធានធន និងតំលៃគណកនី កែតំរូវ

- ប្រាក់ចំណេញនោះត្រូវបានដកចេញ ពន្ធនិងភាគលាភសុទ្ធដែលនឹងត្រូវបង់ ហើយត្រូវ បានផ្ទៀងផ្ទាត់ដោយស្នងការគណកនី

IV- សរុប D ខ្ទង់ត្រូវបូក

- ទុនបំរុងពីការវាយតំលៃឡើងវិញ ដោយមានការយល់ព្រមជាមុនពីធនាគារជាតិនៃកម្ពុជា
- បំណុលបន្ទាប់បន្សំ (Subordinated debt) ដោយមានការយល់ព្រមជាមុនពីធនាគារជាតិនៃកម្ពុជា
- ខ្ទង់ផ្សេងៗទៀត ដោយមានការយល់ព្រមជាមុនពីធនាគារជាតិនៃកម្ពុជា (១) ។

V- សរុប E ខ្ទង់ត្រូវដក

- ភាគកម្មមូលនិធិផ្ទាល់ក្នុងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនានា

- ខ្ទង់ផ្សេងៗ (២) ។

VI- សរុប F សរុបមូលនិធិផ្ទាល់សុទ្ធ = C + D - E

ប្រការ ២ :

មូលនិធិផ្ទាល់សុទ្ធដែលបានគណនាមកនោះ ត្រូវបានយកមកគិតគូរសំរាប់ការគណនាអនុបាតប្រុងប្រយ័ត្នទាក់ទងទៅនឹងសាធនភាព ការបែងបានិភ័យ និងបានិភ័យប្តូរប្រាក់ ។

ប្រការ ៣ :

រាល់លិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

---

(១)ខ្ទង់ផ្សេងៗអាចរួមមានខ្ទង់ទាំងឡាយដូចខាងក្រោមនេះ ៖

. មូលនិធិដែលបានធានាទៅវិញទៅមកយ៉ាងពេញលេញ

. មូលនិធិសាធារណៈដែលបែងចែកសំរាប់ធានាប្រភេទប្រតិបត្តិការឥណទាន

. ឧបត្ថម្ភកធនសាធារណៈ ឬឯកជនដែលមិនត្រូវសងវិញ

(២)ឧទាហរណ៍ : ចំណាយដែលត្រូវចែងចែតសំរាប់ច្រើនការិយបរិច្ឆេទ

ប្រការ ៤ :

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គលេខា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាព និងគ្រប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ នៅក្រោមឱវាទ និងក្រោមអាណាព្យាបាល ធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ។

ប្រការ ៥ :

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ទេសាភិបាល

ហត្ថលេខា និងត្រា

**ជា ចាន់តូ**

★★★

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០០

# ប្រកាសលេខ ធ ៧០០-៥០ ប្រក.

## ស្តីពី

## ដំណើរការគណនេយ្យកម្មសំរាប់ប្រតិបត្តិការរូបិយប័ណ្ណ

***

## ទេសាភិបាល ធនាគារជាតិនៃកម្ពុជា

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣៩៨/៨៥ ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំង ឯកឧត្តម **ជា ចាន់តូ** ជាអគ្គទេសាភិបាលនៃធនាគារជាតិនៃកម្ពុជា
- យោងតាមសំណើរបស់នាយកដ្ឋានត្រួតពិនិត្យ

## សំរេច

**ប្រការ ១ :**

សំរាប់គោលបំណងនៃប្រកាសនេះ ពាក្យមួយចំនួនត្រូវបានកំណត់និយមន័យដូចខាងក្រោម ៖

១- រូបិយវត្ថុរាយការណ៍ មានន័យថា រូបិយវត្ថុដែលបានប្រើសំរាប់កត់ត្រាគណនី និងសំរាប់ធ្វើរបាយការណ៍ហិរញ្ញវត្ថុ ។ ស្ថិតនៅក្នុងរយៈពេលបណ្តោះអាសន្ននៃការងារគណនេយ្យ ប្រាក់ដុល្លារអាមេរិក ត្រូវបានប្រើជារូបិយវត្ថុរាយការណ៍ រហូតដល់ពេលណាដែលដំណើរការបង្រួមរូបនីយកម្មសេដ្ឋកិច្ចកម្ពុជា បានជឿនលឿនសមស្រប ។

២- រូបិយប័ណ្ណ មានន័យថា រូបិយប័ណ្ណក្រៅពីរូបិយវត្ថុរាយការណ៍របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។

៣- អត្រាប្តូរប្រាក់ មានន័យថា អនុបាតរវាងមួយឯកតានៃរូបិយវត្ថុមួយនិងចំនួនទឹកប្រាក់ជារូបិយវត្ថុមួយទៀត ដែលក្នុងនោះ ឯកតានេះអាចត្រូវបានប្តូរពីមួយទៅមួយក្នុងពេលកំណត់មួយ ។

៤- អត្រាប្តូរប្រាក់ដលដៃ (spot rate) មានន័យថា អត្រាប្តូរប្រាក់ដែលបានកំណត់សំរាប់ប្រតិបត្តិការប្តូរដោយប្រគល់ប្រាក់ដល់ដៃភ្លាម ។

៥- អត្រាប្តូរប្រាក់មានកាលកំណត់ (forward rate) មានន័យថា អត្រាប្តូរប្រាក់ដែលបានកំណត់នៅក្នុងកិច្ចសន្យាប្តូរប្រាក់នាកាលបរិច្ឆេទច្បាស់លាស់មួយទៅអនាគត ។

៦- អត្រាប្តូរប្រាក់នៅពេលបិទ (closing rate) មានន័យថា អត្រាប្តូរប្រាក់ផ្ទាល់ដៃនាកាលបរិច្ឆេទនៃការធ្វើតារាងតុល្យការ ។

៧- ប្រតិបត្តិការជារូបិយប័ណ្ណ មានន័យថា ប្រតិបត្តិការមួយដែលត្រូវចារិកឬទាមទារអោយទូទាត់ជារូបិយប័ណ្ណ រួមបញ្ចូលទាំងប្រតិបត្តិការប្តូរប្រាក់ដែលបង្កើតអោយមានស្ថានភាពប្តូរប្រាក់ (foreign exchange position) ។

ប្រការ ២ :

ប្រតិបត្តិការជារូបិយប័ណ្ណត្រូវបានកត់ត្រាស្របតាមបញ្ញត្តិដែលមានចែងក្នុងប្រកាសនេះ ។ ដូច្នេះ ប្រព័ន្ធគណនេយ្យប្រើប្រាស់ដោយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវតែបានរៀបចំយ៉ាងណា ដើម្បីអាចផ្តល់ព័ត៌មានដែលតម្រូវដោយប្រកាសនេះ ។

លោហធាតុមានតំលៃដូចជា មាស និងប្រាក់ដែលត្រូវបានរក្សាទុកតាមទំរង់ដែលអាចជួញដូរបាន ត្រូវអនុវត្តតាមវិធាននៃការវាយតំលៃ ដែលមានចែងនៅក្នុងប្រការ ៦ នៃប្រកាសនេះ ។

ប្រការ ៣ :

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវកត់ត្រាប្រតិបត្តិការប្តូរប្រាក់ផ្ទាល់ដៃ ឬមានកាលកំណត់ក្នុងគណនីដែលបានបើក និងចារិកតាមប្រភេទរូបិយប័ណ្ណមួយៗ ដែលបានប្រើ ។

សំរាប់គោលបំណងនៃប្រកាសនេះ ការទិញឬការលក់រូបិយប័ណ្ណដែលភាគីទាំងអស់មិនបានពន្យារពេលឬបានពន្យារតែក្នុងរយៈពេលជាទំលាប់ ត្រូវបានចាត់ទុកថាជាកិច្ចសន្យាប្តូរប្រាក់ផ្ទាល់ដៃ ។ ដូច្នេះ កិច្ចសន្យាប្តូរប្រាក់ផ្ទាល់ដៃ (spot rate) ត្រូវបានអោយនិយមន័យថាជាកិច្ចសន្យាប្តូរប្រាក់ណាមួយ ក្នុងរយៈពេល ២ថ្ងៃធ្វើការ (2 business days) នៃកាលវសាន (maturity) លើកលែងតែរយៈពេលខ្លីជាងរយៈពេលជាទំលាប់ ឬទាមទារដោយទីផ្សារក្នុងស្រុក ។

សំរាប់គោលបំណងនៃប្រកាសនេះ រាល់ការទិញ ឬការលក់រូបិយប័ណ្ណដែលភាគីទាំងអស់សំរេចពន្យាររយៈពេលជាទំលាប់វែងជាង២ថ្ងៃធ្វើការ ត្រូវបានចាត់ទុកថា ជាកិច្ចសន្យាប្តូរប្រាក់មានកាលកំណត់ (forward contract) ។

ប្រការ ៤ :

បដិភាគនៃការកត់ត្រាគណនេយ្យរូបិយប័ណ្ណទាក់ទងទៅនឹងប្រតិបត្តិការប្តូរប្រាក់ ដូចជាប្រតិបត្តិការដែលជាប់ទាក់ទងដល់ស្ថានភាពរូបិយប័ណ្ណ (foreign currency position) ត្រូវបានកត់ត្រាក្នុង

គណនីស្ថានភាពប្តូរប្រាក់ នៅក្នុងតារាងតុល្យការឬក្រៅតារាងតុល្យការ និងចារិកទៅតាមប្រភេទរូបិយប័ណ្ណដែលបានប្រើ ។

ការកត់ត្រាគណនេយ្យជារូបិយវត្ថុភាពការណ៍ដែលទាក់ទងជាមួយប្រតិបត្តិការប្តូរប្រាក់ ត្រូវបានចុះបញ្ជីកក្នុងគណនីបដិភាគស្ថានភាពប្តូរប្រាក់ នៅក្នុងតារាងតុល្យការឬក្រៅតារាងតុល្យការ ។

ជាលទ្ធផល ប្រតិបត្តិការជារូបិយប័ណ្ណ និងជារូបិយវត្ថុភាពការណ៍ត្រូវបានកត់ត្រាចូលក្នុងសៀវភៅធំ (ledger) សមស្រប ហើយសៀវភៅធំនីមួយៗត្រូវមានតុល្យភាពដោយប្រើគណនីឆ្លុះបញ្ចាំង (mirror accounts) ដូចខាងក្រោម ៖

★ ស្ថានភាពប្តូរប្រាក់ជារូបិយប័ណ្ណចែកជា ៖

- ស្ថានភាពប្តូរប្រាក់នៅក្នុងតារាងតុល្យការ
- ស្ថានភាពប្តូរប្រាក់នៅក្រៅតារាងតុល្យការ

★ ស្ថានភាពប្តូរប្រាក់ជារូបិយវត្ថុភាពការណ៍សមមូល (ឬតំលៃបដិភាគ) ចែកជា ៖

- ស្ថានភាពប្តូរប្រាក់សមមូលនៅក្នុងតារាងតុល្យការ
- ស្ថានភាពប្តូរប្រាក់សមមូលនៅក្រៅតារាងតុល្យការ ។

**ប្រការ ៥ :**

ដើមទុនដែលបានមកពីការទិញ ឬលក់ក្នុងប្រតិបត្តិការប្តូរប្រាក់ផាល់ដៃ (spot rate) ដែលមានកាលវសាន (maturity) ជាទំលោប់២ថ្ងៃធ្វើការ និងក្នុងប្រតិបត្តិការប្តូរប្រាក់មានកាលកំណត់ ត្រូវតែកត់ត្រាក្នុងគណនីក្រៅតារាងតុល្យការសមស្រប នាកាលបរិច្ឆេទដែលប្រតិបត្តិការកើតឡើង ។ នៅពេលប្រគល់រូបិយប័ណ្ណប្រតិបត្តិការត្រូវបានកត់ត្រាចូលក្នុងតារាងតុល្យការរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។

**ប្រការ ៦ :**

នាកាលបរិច្ឆេទនៃរបាយការណ៍គណនេយ្យនីមួយៗ ទ្រព្យសកម្ម ទ្រព្យអកម្ម ឬខ្ទង់ក្រៅតារាងតុល្យការ ត្រូវបានអោយតំលៃតាមថ្លៃទីផ្សារ ។ អត្រាទីផ្សារដែលអនុវត្តចំពោះខ្ទង់ទ្រព្យសកម្ម និងខ្ទង់ទ្រព្យអកម្ម និងចំពោះការសន្យាប្តូរប្រាក់ផាល់ដៃ គឺជាអត្រាប្តូរប្រាក់នៅពេលបិទនៃរូបិយប័ណ្ណដែលពាក់ព័ន្ធ ។

អត្រាប្តូរប្រាក់ទីផ្សារដែលអនុវត្តចំពោះការសន្យាប្តូរប្រាក់មានកាលកំណត់ គឺជាអត្រាប្តូរប្រាក់មានកាលកំណត់នៃរូបិយប័ណ្ណពាក់ព័ន្ធ សំរាប់រយៈកាលដែលនៅសល់ ដូចជាអត្រាប្តូរប្រាក់មានកាលកំណត់នៅទីផ្សារត្រូវស្របទៅនឹងកាលវសាននៃការសន្យា ។

**ប្រការ ៧ :**

នាកាលបរិច្ឆេទរបាយការណ៍គណនេយ្យនីមួយៗ វិសមភាពនៃចំនួនប្រាក់ជារូបិយវត្ថុរបាយការណ៍ ដែលបានមកពីការវាយតំលៃគណនីស្ថានភាពប្តូរប្រាក់ ស្របតាមបញ្ញត្តិនៃប្រការ ៥ ម្យ៉ាងនិងម្យ៉ាងទៀត ចំនួនប្រាក់ដែលបានបង្ហាញក្នុងគណនីបដិភាគស្ថានភាពប្តូរប្រាក់ ត្រូវបានកត់ត្រាចូលក្នុងគណនីចំណេញខាត ។ បដិភាគនៃការកត់ត្រានេះ ត្រូវបានកត់ត្រាចូលក្នុងគណនីបដិភាគស្ថានភាពប្តូរប្រាក់ចារិកជារូបិយវត្ថុរបាយការណ៍ ។

នៅពេលដែលមិនទាន់អាចកត់ត្រាគំលាតនូវលើគណនីក្នុងតារាងតុល្យការបាន ដោយកត់ត្រាផលលាភនៃគណនីក្រៅតារាងតុល្យការ និងផ្ទុយមកវិញ ប្រាក់ចំណេញនិងខាតដែលបានកត់ត្រាក្នុងគណនីចំណេញខាត និងដែលកើតចេញពីស្ថានភាពប្តូរប្រាក់ក្រៅតារាងតុល្យការ ត្រូវតែមានតុល្យភាពដោយប្រើគណនីមួយដែលធ្វើអោយមានតុល្យភាពនៃតារាងតុល្យការ ។

វិសមភាពទាំងឡាយដែលទាក់ទងនឹងប្រតិបត្តិការ ដែលក្នុងនោះហានិភ័យនៃការប្តូរប្រាក់រ៉ាប់រងដោយរដ្ឋ ត្រូវតែកត់ត្រាចូលក្នុងគណនីពិសេស ។

**ប្រការ ៨ :**

ចំណូលនិងចំណាយបង្គរជារូបិយប័ណ្ណដែលទាក់ទងនឹងគណនីទាននិងកម្ចី មូលប័ត្រ ឬប្រតិបត្តិការក្រៅតារាងតុល្យការ ត្រូវបានវាយតំលៃតាមអត្រាប្តូរប្រាក់ដល់ដៃនៃរូបិយប័ណ្ណដែលពាក់ព័ន្ធ ហើយត្រូវកត់ត្រាចូលក្នុងគណនីចំណេញខាត តាមអត្រា ដែលកំណត់ដោយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងយ៉ាងយឺតបំផុតនៅកាលបរិច្ឆេទនៃរបាយការណ៍គណនេយ្យ ។

ចំណូលដែលត្រូវទទួល និងចំណាយដែលត្រូវសងជារូបិយប័ណ្ណមិនបង្គរ ទាក់ទងនឹងប្រតិបត្តិការក្នុងតារាងតុល្យការឬក្រៅតារាងតុល្យការ ត្រូវតែបង្ហាញនៅក្នុងគណនីដោយឡែក នៅពេលណាដែលចំណូលនិងចំណាយទាំងនេះ ត្រូវបានការពារការខាតបង់ (hedged) ។

**ប្រការ ៩ :**

ដើម្បីធានាអោយការធ្វើរបាយការណ៍ពីហានិភ័យប្តូរប្រាក់ស៊ីសង្វាក់គ្នាទូទាំងប្រព័ន្ធធនាគារ យ៉ាងហោចណាស់ ការវាយតំលៃឡើងវិញត្រូវតែអនុវត្តនាកាលបរិច្ឆេទបិទបញ្ជីនៅខែនីមួយៗ ។ ប្រសិនបើកាលបរិច្ឆេទនេះមិនមែនជាថ្ងៃធ្វើការ ការវាយតំលៃបិទបញ្ជីត្រូវធ្វើនៅថ្ងៃធ្វើការមុននោះ ។

**ប្រការ ១០ :**

រាល់លិខិតបទដ្ឋានទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ១១ :

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គលេខា គ្រប់នាយកដ្ឋាន អង្គភាព គ្រប់គ្រឹះស្ថានធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ នៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ។

ប្រការ ១២ :

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសាភិបាល

ហត្ថលេខា និងត្រា

ជា ចាន់តូ

★★★

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០០

## ប្រកាសលេខ ធ ៧០០-៥១ ប្រក.

## ស្តីពីចំណាត់ថ្នាក់ និងសំវិធានធនលើបំណុលអាក្រក់ និងបំណុលសង្ស័យរួមទាំងការប្រាក់ដែលបានព្យួរ

***

## ទេសាភិបាល ធនាគារជាតិនៃកម្ពុជា

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣៩៨/៩៥ ចុះថ្ងៃទី ១០ ខែមីនា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង ឯកឧត្តម **ជា ចាន់តូ** ជាអគ្គទេសាភិបាលនៃធនាគារជាតិនៃកម្ពុជា
- យោងតាមសំណើរបស់នាយកដ្ឋានត្រួតពិនិត្យ

## សំរេច

ប្រការ ១ :

ធនាគារត្រូវរៀបចំប្រព័ន្ធព័ត៌មានគណនេយ្យផ្ទៃក្នុងរបស់ខ្លួន ដើម្បីអាចមានលទ្ធភាពផ្តល់ជាអចិន្ត្រៃយ៍ជូនធនាគារជាតិនៃកម្ពុជា នូវព័ត៌មានស្របតាមបញ្ញត្តិនៃប្រកាសនេះ ។

ប្រការ ២ :

ធនាគារត្រូវធ្វើចំណាត់ថ្នាក់ទ្រព្យសកម្មរបស់ខ្លួន ជាពិសេសសំណុំឥណទាន (loan portfolio) ចំពោះអតិថិជនគ្រប់ប្រភេទ (ធនាគារ ឯកត្តជន ក្រុមហ៊ុនអាជីវកម្ម និងអង្គភាពរដ្ឋាភិបាល) និងការសន្យាក្រៅតារាងតុល្យការរបស់ខ្លួន ជា ៤ ថ្នាក់ ដូចមានកំណត់ក្នុងឧបសម្ព័ន្ធ ។

ប្រការ ៣ :

រាល់ទ្រព្យសកម្មនិងការសន្យាដែលស្ថិតក្នុងចំណាត់ថ្នាក់បំណុលក្រោមស្តង់ដារ បំណុលសង្ស័យ និងបំណុលបាត់បង់ ត្រូវតែបានកត់ត្រាក្នុងខ្ទង់ដែលពាក់ព័ន្ធ ។ ចំណាត់ថ្នាក់ទាំងនេះ ត្រូវតែបញ្ចូលទៅក្នុងរបាយការណ៍តាមការតំរូវរបស់ធនាគារជាតិនៃកម្ពុជា ជាពិសេសរបាយការណ៍ទាំងឡាយស្តីពីទ្រព្យសកម្ម និងខ្ទង់ក្រៅតារាងតុល្យការ ។

ប្រការ ៤ :

យោងទៅតាមចំណាត់ថ្នាក់ដែលបានធ្វើ កំរិតអប្បបរមានៃការធ្វើសំវិធានធន ត្រូវមានដូចខាងក្រោមនេះ ដោយមិនគិតពីទ្រព្យសកម្មដែលបានរក្សាទុកជាទ្រព្យសំរាប់ធានា (លើកលែងតែសាច់ប្រាក់) ៖

- បំណុលក្រោមស្តង់ដារ : ម្ភៃភាគរយ (២០ %)
- បំណុលសង្ស័យ : ហាសិបភាគរយ (៥០ %)
- បំណុលបាត់បង់ : មួយរយភាគរយ (១០០ %) ។

ប្រការ ៥ :

ការធ្វើសំវិធានធនជាក់លាក់ (specific provision) ត្រូវបានកត់ត្រានៅក្នុងគណនីរបស់ធនាគារ និងត្រូវបានដកចេញពីគណនីចំណេញខាតនៅក្នុងខែដែលត្រូវធ្វើសំវិធានធននេះ ។ សំវិធានធនមិនអាចពន្យារទៅគ្រាបន្ទាប់ទៀតទេ ។ នៅពេលណាដែលសមតុល្យគណនីរបស់អតិថិជនមានបញ្ចូលការប្រាក់ ក្នុងនោះគណនីបរិភាគត្រូវបានកត់ត្រាជាការប្រាក់ព្យួរ (មើលប្រការ ៦ ខាងក្រោម) ចំនួនប្រាក់នេះមិនត្រូវយកមកគិតសំរាប់គណនាសំវិធានធនទេ ។

ប្រការ ៦ :

ស្របតាមមូលដ្ឋានបង្គរនៃគណនេយ្យ (accrual basis accounting) ការប្រាក់បង្គរលើឥណទានអតិថិជន ត្រូវបានកត់ត្រាជាចំណូលក្នុងគណនីចំណេញខាត ។ ប៉ុន្តែ មិនត្រូវអនុវត្តតាមទំរង់ការនេះ ចំពោះទ្រព្យសកម្មទាំងឡាយណាដែលត្រូវបានចាត់ថ្នាក់ជាបំណុលក្រោមស្តង់ដារ បំណុលសង្ស័យ ឬបំណុលបាត់បង់ ។ ក្នុងស្ថានភាពនេះ ការប្រាក់បង្គរត្រូវកត់ត្រាខាងឥណទាននៃគណនីសំរាប់ព្យួរ ។

ប្រការ ៧ :

ការរំលោភលើបញ្ញត្តិនៃប្រកាសនេះ ត្រូវទទួលរងនូវទណ្ឌកម្មខាងវិន័យដូចមានចែងក្នុងមាត្រា ៥២ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។

ប្រការ ៨ :

រាល់លិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៩ :

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គលេខា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាព និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នៅក្រោមឱវាទនិងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ។

ប្រការ ១០ :

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសាភិបាល

ជា ចាន់តូ

★★★

ឧបសម្ព័ន្ធនៃប្រកាសស្តីពីចំណាត់ថ្នាក់និងសំវិធានធន
លើបំណុលអាក្រក់និងបំណុលសង្ស័យ រួមទាំងការប្រាក់ដែលបានព្យួរ

ចំណាត់ថ្នាក់ឥណទាន

| លក្ខណៈវិនិច្ឆ័យ | ដំណើរការសងប្រាក់ | ស្ថានភាពហិរញ្ញវត្ថុ |
|---|---|---|
| **បំណុលស្តង់ដារ**<br>- ទ្រព្យសកម្មដំណើរការ<br>..............................<br>- ទ្រព្យសកម្មដំណើរការ<br>.............................. | - ទៀងពេល<br>.....................................<br>- ហួសកាលកំណត់>៣០ថ្ងៃ<br>..................................... | - ស្ថានភាពហិរញ្ញវត្ថុល្អបំផុត<br>.....................................<br>- ស្ថានភាពហិរញ្ញវត្ថុល្អ<br>..................................... |
| - ទ្រព្យសកម្មមានការធានាពេញលេញ (ប្រាក់ដើមនិងការប្រាក់ ដោយសាច់ប្រាក់និងជំនួសសាច់ប្រាក់) | - អាចមានការលំបាកផ្សេងៗក្នុងសេវា | - បង្ហាញនូវចំណុចខ្សោយផ្នែកហិរញ្ញវត្ថុ |

| | | |
|---|---|---|
| បំណុលក្រោមស្តង់ដា | ហួសកាលកំណត់>៩០ថ្ងៃ<br>- បុរេប្រទានលើសកំរិតឥណទាន ៩០ថ្ងៃ ឬច្រើនជាង<br>- ប្រាក់បញ្ញើលើគណនី < ការប្រាក់ដល់កាលកំណត់ ៩០ ថ្ងៃ | ទ្រព្យសកម្មមិនត្រូវបានការពារពេញលេញតទៅទៀតដោយស្ថានភាពហិរញ្ញវត្ថុរបស់កូនបំណុលដែលអាចមានការលំបាកក្នុងការសងបំណុល |
| បំណុលសង្ស័យ | ហួសកាលកំណត់>១៨០ថ្ងៃ<br>- បុរេប្រទានលើសកំរិតឥណទាន ១៨០ថ្ងៃ ឬ ច្រើនជាង<br>- ប្រាក់បញ្ញើលើគណនី<ការប្រាក់ដល់កាលកំណត់១៨០ថ្ងៃ | ចំណុចខ្សោយបច្ចុប្បន្ននិងអនាគតរបស់កូនបំណុលធ្វើឲ្យការសងបំណុលគ្រប់ចំនួនត្រូវមានការសង្ស័យឬមិនអាចសងបាន ។ លទ្ធភាពនៃការខាតបង់ខ្ពស់ ប៉ុន្តែកត្តាពិសេសចំនួនដែលអាចបង្កើនកំលាំងទ្រព្យសកម្មអនុញ្ញាតអោយពន្យារការធ្វើចំណាត់ថ្នាក់ជាការខាតបង់ ។ |
| បំណុលបាត់បង់ | ហួសកាលកំណត់>៣៦០ថ្ងៃ<br>- បុរេប្រទានលើសកំរិតឥណទាន ៣៦០ថ្ងៃ ឬច្រើនជាង<br>- ប្រាក់បញ្ញើលើគណនី<ការប្រាក់ដល់កាលកំណត់ ៣៦០ថ្ងៃ | ទ្រព្យសកម្មដែលត្រូវបានធ្វើចំណាត់ថ្នាក់ជាខាតបង់សន្មតថា មិនអាចប្រមូលបានតែបើប្រមូលវិញក៏ស្តួចស្តើង |

<u>**កំណត់សំគាល់ :**</u>

១- ចំណាត់ថ្នាក់ត្រូវធ្វើលើរាល់ឥណទានដោយផ្ទាល់ និងប្រយោល ដោយគិតទាំងឲ្យខ្ចី គណនីលើសសមតុល្យ ទ្រព្យសម្បត្តិដែលរឹបអូសបានដោយសារកិច្ចសន្យាបំណុលពីមុន ការវិនិយោគ ភាគកម្ម និងការសន្យាក្រៅតារាងតុល្យការ (លិខិតឥណទាន លិខិតធានា ។ល។)

២- ឥណទាននិងបុរេប្រទានដែលបានរៀបចំឡើងវិញ គឺជាឥណទានដែលបានធ្វើបុនហិរញ្ញប្បទាន ធ្វើការវិភាគថ្មី ផ្តល់សាឡើងវិញ ឬបានកែប្រែកាលកំណត់និងល័ក្ខខ័ណ្ឌសមស្របនឹងអ្នកខ្ចី ព្រោះតែចំណុចខ្សោយលើស្ថានភាពហិរញ្ញវត្ថុ ឬលទ្ធភាពសងបំណុលក៏ដោយ ការរៀបចំឡើងវិញមិនអាចនាំទៅដល់ការកែអោយប្រសើរឡើង លើកលែងតែមានភស្តុតាងរឹងមាំនៃការកែលំអនូវស្ថានភាពហិរញ្ញវត្ថុរបស់អតិថិជន ។

★★★

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០០

## ប្រកាសលេខ ធ ៧០០-៥២ ប្រក.

## ស្តីពីការត្រួតពិនិត្យហានិភ័យធំៗរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

***

### ទេសាភិបាល ធនាគារជាតិនៃកម្ពុជា

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣៩៨/៩៥ ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំង ឯកឧត្តម **ជា ចាន់តូ** ជាអគ្គទេសាភិបាលនៃធនាគារជាតិនៃកម្ពុជា
- យោងតាមសំណើរបស់នាយកដ្ឋានត្រួតពិនិត្យ

### សម្រេច

**ប្រការ ១ :**

ត្រូវឲ្យធនាគាររក្សាឲ្យបានគ្រប់ពេលវេលា តាមលក្ខខណ្ឌដែលមានចែងនៅក្នុងប្រកាសនេះ នូវអនុបាតអតិបរមាចំនួនម្ភៃភាគរយ (២០%) រវាងហានិភ័យសរុបដែលកើតចេញពីប្រតិបត្តិការជាមួយនឹងអត្ថគាហកជាឯកត្តជននីមួយៗ និងមូលនិធិផ្ទាល់សុទ្ធរបស់ខ្លួន ។

ហានិភ័យធំៗ (large exposures) មានន័យថាហានិភ័យសរុបដែលកើតចេញពីប្រតិបត្តិការជាមួយអត្ថគាហកតែម្នាក់ដែលហានិភ័យនេះលើសពីម្ភៃភាគរយ (២០%) នៃមូលនិធិផ្ទាល់សុទ្ធរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។

**ប្រការ ២ :**

សំរាប់គោលបំណងនៃប្រកាសនេះ មូលនិធិផ្ទាល់សុទ្ធត្រូវបានគណនា ស្របតាមបញ្ញត្តិនៃប្រកាសស្តីពីការគណនាមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ ។

**ប្រការ ៣ :**

សំរាប់គោលបំណងនៃប្រកាសនេះ ហានិភ័យដែលផ្សារភ្ជាប់ទៅនឹងហានិភ័យនៃគុណវិបត្តិរបស់បដិភាគី គឺជាខ្ទង់ដែលត្រូវបានថ្លឹងដូចមានកំណត់ក្នុងប្រការ៣ នៃប្រកាសស្តីពីអនុបាតសាធនភាព

របស់ធនាគារ ។ ប៉ុន្តែ ឥណទានដែលបានផ្តល់ទៅអោយសមាជិកក្រុមប្រឹក្សា ស្របតាមបញ្ញត្តិនៃប្រកាស ស្តីពីការផ្តល់អោយសមាជិកក្រុមប្រឹក្សារបស់ធនាគារ មិនត្រូវបានចាត់ទុកជាហានិភ័យធំ ។

**ប្រការ ៤ :**

ត្រូវបានចាត់ទុកថាជាអត្ថគាហកតែម្នាក់ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានចំណងទាក់ទងគ្នាទៅវិញទៅមក ព្រោះថាបញ្ហាហិរញ្ញវត្ថុនៃរូបវន្តបុគ្គល ឬនីតិបុគ្គលម្នាក់នោះពិត ឬទំនងជួបប្រទះជៀសមិនផុត ពិតជានាំអោយមានបញ្ហាហិរញ្ញវត្ថុដូចគ្នា ចំពោះគេទាំងអស់គ្នា ។

ជាពិសេស ចំណងទាក់ទងបែបនេះកើតមានរវាងរូបវន្តបុគ្គល ឬនីតិបុគ្គលពីរ ឬច្រើននៅពេលណាដែល ៖

- រូបវន្តបុគ្គល ឬនីតិបុគ្គលម្នាក់គ្រប់គ្រងដោយផ្ទាល់ ឬដោយប្រយោលលើអ្នកផ្សេងទៀត
- រូបវន្តបុគ្គល ឬនីតិបុគ្គលពីរជាបុគ្គលសម្ព័ន្ធនៃក្រុមហ៊ុនតែមួយ
- រូបវន្តបុគ្គល ឬនីតិបុគ្គលស្ថិតនៅក្រោមការគ្រប់គ្រងប្រតិបត្តិ (de facto management) តែមួយ
- រូបវន្តបុគ្គល ឬនីតិបុគ្គលម្នាក់មានភាគហ៊ុននៅក្នុងក្រុមហ៊ុនផ្សេងទៀត លើសពីដប់ភាគរយ (១០%) ហើយពួកគេត្រូវបានចងភ្ជាប់ដោយកិច្ចសន្យាធានាសងជំនួស ឬមានទំនាក់ទំនងពីអាជីវកម្មពិសេសជាមួយគ្នា ដូចជា កិច្ចសន្យាបន្ទាប់បន្សំ សិទ្ធិផ្តាច់មុខ (franchise) ។

ធនាគារជាតិនៃកម្ពុជាចាត់ទុកអតិថិជនមួយក្រុមថាជាអត្ថគាហកតែម្នាក់ ប្រសិនបើចំណងទាក់ទងរវាងពួកគេមានដូច្នេះមែន ។

**ប្រការ ៥ :**

ហានិភ័យដែលបានកំណត់ក្នុងប្រការ ៣ ត្រូវស្ថិតនៅក្រោមនីតិវិធីនៃការគ្រប់គ្រងនិងការត្រួតពិនិត្យផ្ទៃក្នុង ជាពិសេស ដោយកំណត់ព្រំដែនលើការប្រគល់សិទ្ធិក្នុងការសំរេចឥណទានឬការសន្យា ធ្វើយ៉ាងណាអោយចំនួនអតិបរមានៃអនុបាតដែលមានចែងក្នុងប្រការ ២ ត្រូវបានគោរពគ្រប់ពេលវេលា ។

ធនាគារត្រូវប្រកាន់យកជំហានចាំបាច់ទាំងអស់ ក្នុងការរក្សាទុកនូវការកត់ត្រាមជ្ឈការពេញលេញចំពោះការសន្យារបស់ខ្លួន ជាពិសេស ការសន្យាដែលផ្តល់ចំពោះអត្ថគាហកដែលមានចំណងទាក់ទងគ្នាទៅវិញទៅមក តាមស្មារតីប្រការ ៤ នៃប្រកាសនេះ ។

ធនាគារជាតិនៃកម្ពុជា ត្រូវឲ្យគេផ្តល់នូវរបាយការណ៍ស្តីពីជំហានទាំងឡាយដែលបានធ្វើ ។

**ប្រការ ៦ :**

ធនាគារត្រូវធ្វើប្រតិវេទន៍ តាមត្រីមាសនីមួយៗ អំពីហានិភ័យធំៗរបស់ខ្លួន ស្របតាមគំរូដែលធនាគារជាតិនៃកម្ពុជាបានដាក់ចេញ ។

**ប្រការ ៧ :**

រាល់លិខិតបទដ្ឋានទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៨ :**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គលេខា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាពគ្រប់គ្រឹះស្ថានធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ នៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ៩ :**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសាភិបាល

ហត្ថលេខា និងត្រា

ជា ចាន់តូ

★★★

## ២- នីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

## ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០០

## ប្រកាសលេខ ១០៥ កឧ.ប្រក

***

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។
- បានឃើញព្រះរាជក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ ១៩៩៩ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។
- បានឃើញលិខិតលេខ ០៣៣/០០ ត.វ.ក ចុះថ្ងៃទី៦-០១-២០០០ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

- បានពិនិត្យលិខិតលេខ ៩៣/២០០០ ប.ស្ថ ចុះថ្ងៃទី៣០-០២-២០០០ របស់ក្រសួងបរិស្ថាន ។
- បានឃើញលិខិតលេខ ៤២៩៦ សអ.ស ចុះថ្ងៃទី១៣-១២-១៩៩៦ របស់គណៈក្រុងភ្នំពេញ ស្តីពីការអនុញ្ញាតអោយសាងសង់អាគារកាត់ដេរ ។
- យោងពាក្យស្នើរបស់ក្រុមហ៊ុន អិម អេស អ៊ិនធើណេសិនណល ហ្គាមេន ខមភេនី ថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ ២០០០ ។

**សំរេច**

**ប្រការ ១ :** អនុញ្ញាតឲ្យក្រុមហ៊ុន "អិម អេស អ៊ិនធើណេសិនណល ហ្គាមេន ខមភេនី" (M.S INTERNATIONAL GARMENT COMPANY LTD) តំណាងដោយលោក KIM DO SAM សញ្ជាតិ កូរ៉េ ភេទប្រុស អាយុ ៥៩ ឆ្នាំ កាន់លិខិតឆ្លងដែនលេខ SC 067 1843 បង្កើតរោងចក្រកាត់ដេរសំលៀកបំពាក់នាំចេញ ដែលមានផ្លាកឈ្មោះថា "រោងចក្រកាត់ដេរ អិម អេស អ៊ិនធើណេសិនណល" មានទីតាំងស្ថិតនៅ ភូមិទួលសង្កែ សង្កាត់ទួលសង្កែ ខ័ណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។

**ប្រការ ២ :** ការរៀបចំអគារនិងគ្រឿងចក្រ ក្រុមហ៊ុនត្រូវធ្វើទៅតាមប្លង់ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានសំរេចក្នុងរយៈពេល ០៣ខែ ដោយរាប់បញ្ចូលទាំងរយៈពេលដំណើរការសាកល្បងផង ។

**ប្រការ ៣ :** រោងចក្រនេះត្រូវបានអនុញ្ញាតឲ្យ "កាត់-ដេរ សំលៀកបំពាក់" ទៅតាមគំរូដែលបានតំកល់ទុក ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែ អំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ ៤ :** ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ" របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

**ប្រការ ៥ :** រាល់ការនាំចេញផលិតផលសំរេច ក្រុមហ៊ុនត្រូវសុំវិញ្ញាប័ត្របញ្ជាក់ផលិតកម្ម ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ ៦ :** ក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និងគុណភាពផលិតផលព្រមទាំងត្រូវគោរពឲ្យបានម៉ឺងម៉ាត់នូវច្បាប់ស្តីពីការងារ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ និងច្បាប់បទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្មរបស់ក្រុមហ៊ុន ។

**ប្រការ ៧ :** ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

**ប្រការ ៨ :** អគ្គនាយកឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលរាជធានីភ្នំពេញ និងប្រធានក្រុមហ៊ុន គិម ឌេស គិនធើណេសិនណល ហ្គ្រេអេន ឧអរោពី ត្រូវអនុវត្ត ប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ៩ :** ប្រកាសនេះមានអានុភាព គតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ហត្ថលេខា និងត្រា

ស៊ុយ សែម

***

## ៣- និស្តីការរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

### ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ ២០០០

### ប្រកាសលេខ ០២៨ បទ.ប្រក

### ស្តីពីការតភ្ជាប់ខ្សែបណ្តាញទូរស័ព្ទ

***

### រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើអោយច្បាប់ស្តីពីការ រៀបចំ និងប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ប្រកាសអោយប្រើដោយច្បាប់ ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញ សេចក្តីសំរេចលេខ១៥៤ សសរ. ចុះថ្ងៃទី១១-១២-១៩៩១ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីឋានានុក្រមគ្រប់គ្រងតម្លៃ
- សេចក្តីសំរេចអង្គប្រជុំក្រសួងនាថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ ២០០០

## សំរេច

### ១- និយមន័យ

នៅក្នុងបទបញ្ញត្តិនេះ:

១.១- ក្រសួងប.ទ. គឺជាក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍កម្ពុជាដែលមានភារកិច្ចបង្កើតនិងអនុវត្ត បទបញ្ញត្តិក្នុងវិស័យទូរគមនាគមន៍ ។

១.២- តណភនេយ្យធ្លាប់ មានន័យថាការប្តូរទិន្នន័យនាទីសន្ទនានិងការទូទាត់ប្រាក់ជាដើម ត្រូវធ្វើដោយផ្ទាល់ រវាងបណ្តាញដើម និងបណ្តាញចុងក្រោយ ។

១.៣- ប្រតិបត្តិករ មានន័យថាអង្គភាពដែលបំរើសេវាដោយប្រើបណ្តាញទូរគមនាគមន៍ ។

១.៤- POI (Point of Interconnect) ជាចំណុចតភ្ជាប់រវាងប្រព័ន្ធ ។

១.៥- USO (Universal Service Obligation) កាតព្វកិច្ចសេវាសកល ។

### ២- សេចក្តីតម្រូវការនៃការតភ្ជាប់រវាងប្រព័ន្ធទូរស័ព្ទ

២.១- គ្រប់ប្រតិបត្តិករទាំងអស់មិនត្រូវធ្វើឲ្យមានការរាំងស្ទះដោយចេតនានូវចរន្តសេវាទូរស័ព្ទដែលហៅចេញពីប្រព័ន្ធរបស់ខ្លួន ឬហៅមកប្រព័ន្ធរបស់ខ្លួន ឬឆ្លងកាត់តាមប្រព័ន្ធរបស់ខ្លួនឡើយ លើកលែងតែបានទទួលសេចក្តីអនុញ្ញាតជាលាយលក្ខអក្សរអំពីក្រសួង ប.ទ. ។

២.២- គ្រប់ប្រតិបត្តិករទាំងអស់ត្រូវបញ្ជូនលេខទូរស័ព្ទដែលហៅចេញ និងលេខទូរស័ព្ទដែលហៅចូលទៅប្រព័ន្ធ ទូរស័ព្ទដែលទទួល ។

២.៣- ប្រតិបត្តិករទាំងអស់ត្រូវរក្សាគុណភាពសេវាហៅចេញឬចូល ទៅឬមកពីបណ្តាញដទៃយ៉ាងហោចណាស់ឲ្យ មានគុណភាពខ្ពស់ដូចក្នុងបណ្តាញរបស់ខ្លួន ។

២.៤- ភារកិច្ចតម្លើង រក្សាហើយនិងការបង់ប្រាក់ចំពោះការតភ្ជាប់ដោយផ្ទាល់រវាងប្រព័ន្ធពីរត្រូវកំណត់ឲ្យបានច្បាស់នៅក្នុងពេលចរចាររវាងប្រតិបត្តិករជាគូភាគីនៃការតភ្ជាប់ ។

### ៣- ការផ្លាស់ប្តូរប្រព័ន្ធ

៣.១- ម្ចាស់ប្រព័ន្ធដែលមានបំណងកែប្រព័ន្ធដែលអាចតម្រូវឲ្យមានការកែប្រព័ន្ធប្រតិបត្តិករដទៃក្នុងទ្រង់ទ្រាយធំ ត្រូវជូនដំណឹងជាលាយលក្ខអក្សរមកក្រសួង ប.ទ. អោយបានឆាប់បំផុតហើយមិនត្រូវអោយតិចជាង ៧ខែ គិតចាប់តាំងពីថ្ងៃទទួលសំណើរហូតដល់ពេលកំណត់ថ្ងៃត្រូវកែប្រព័ន្ធ ។

៣.២- ផ្អែកតាមគោលការណ៍អព្យាក្រឹត្យនិងយុត្តិធម៌ ក្រសួងប.ទ និងធ្វើការកំណត់ថាភាគីណាត្រូវចេញថ្លៃកែប្រព័ន្ធ ។

៤- តម្លៃនៃការតភ្ជាប់

៤.១- វិធីតភ្ជាប់រវាងប្រព័ន្ធមានមូលដ្ឋានដូចខាងក្រោម

- សំរាប់បណ្តាញទូរស័ព្ទអចល័តតម្លៃត្រូវកំណត់តាមលេខកូដតំបន់ គឺប្រើលេខកូដតំបន់ដើម្បីដឹងទីតាំងរបស់ អ្នកហៅនិងអ្នកទទួល ។
- សំរាប់បណ្តាញទូរស័ព្ទចល័តតម្លៃតភ្ជាប់ត្រូវកំណត់យកតម្លៃតែមួយដូចគ្នាក្នុងព្រះរាជាណាចក្រកម្ពុជា ដោយមិនគិតអំពីទីតាំងរបស់អ្នកទទួលឡើយ ។

៤.២- ទំរង់និងកំរិតនៃតំលៃតភ្ជាប់មានចែងដូចខាងក្រោម ។ តំលៃខាងក្រោមត្រូវបង់ដោយប្រតិបត្តិករនៃប្រព័ន្ធរបស់អ្នកហៅចេញ ។

៤.២.១- ទូរស័ព្ទអចល័ត ----> ទូរស័ព្ទអចល័តនៅក្រុងភ្នំពេញ ឬ

ទូរស័ព្ទអចល័ត ----> ទូរស័ព្ទអចល័តនៅក្នុងខេត្ត, បើចំណុចតភ្ជាប់ (POI) ស្ថិតនៅក្នុងខេត្តនោះ ២ សេន ក្នុង១នាទី

៤.២.២- ទូរស័ព្ទចល័ត -----> ទូរស័ព្ទអចល័តនៅក្រុងភ្នំពេញ

៥ សេន ក្នុង១នាទី

៤.២.៣- ទូរស័ព្ទអចល័ត ឬចល័ត ---> ទូរស័ព្ទអចល័តដែលពុំមានបំរើសេវានៅខេត្ត

៥ សេន ក្នុង១នាទី

៤.២.៤- ទូរស័ព្ទអចល័ត ឬចល័ត ----> ទូរស័ព្ទចល័តដែលមានបំរើនៅខេត្តផងនិងទីក្រុងភ្នំពេញផង ៧ សេន ក្នុង១នាទី

៤.២.៥- ទូរស័ព្ទចល័ត ----> ទូរស័ព្ទអចល័តនៅខេត្ត, បើចំណុចតភ្ជាប់ស្ថិតនៅភ្នំពេញ

១៨ សេន ក្នុង១នាទី

៤.២.៦- ទូរស័ព្ទអចល័ត -----> ទូរស័ព្ទអចល័តនៅខេត្ត, បើចំណុចតភ្ជាប់ស្ថិតនៅភ្នំពេញ

១៨ សេន ក្នុង១នាទី

៤.២.៦.១- ទូរស័ព្ទហៅស្ថិតនៅភ្នំពេញ

១៨ សេន ក្នុង១នាទី

៤.២.៦.២- ទូរស័ព្ទហៅស្ថិតនៅខេត្តដទៃ

៩ សេន ក្នុង១នាទី

៤.២.៦.៣- ទូរស័ព្ទហៅស្ថិតនៅក្នុងខេត្តជាមួយគ្នា

២ សេន ក្នុង១នាទី

៤.២.៧- បណ្តាញក្នុងប្រទេស -----> បណ្តាញអន្តរជាតិ (ហៅចេញទៅបរទេស)

១០០% នៃតម្លៃរបស់ក្រសួង ប.ទ.

៤.២.៨- បណ្តាញអន្តរជាតិ -----> បណ្តាញក្នុងប្រទេស (ហៅចូលពីបរទេស)

២ សេន ក្នុងមួយនាទី

៤.២.៩- តម្លៃផ្សេងទៀត

៤.២.៩.១- តម្លៃស្ពានបណ្តាញបណ្តាញតភ្ជាប់រវាងប្រព័ន្ធពីរ ត្រូវកំណត់ដោយអ្នកផ្តល់ផ្គង់នៃការតភ្ជាប់ ។

៤.២.៩.២- តម្លៃឆ្លងកាត់ Transit Swich : ១សេនក្នុង១នាទី ។ អនុវត្តន៍តែក្នុងករណីមានការឆ្លងកាត់ជាក់ស្តែង ។

៤.២.៩.៣- ត្រូវបង់ប្រាក់ ០.២ សេនអាមេរិក/នាទី សំរាប់គ្រប់ចរន្តសេវាតភ្ជាប់រវាងប្រព័ន្ធ សម្រាប់មូលនិធិកាតព្វកិច្ចសេវាសកល (USO) ។ ប្រាក់នេះត្រូវបង់ទៅក្រសួង ប.ទ. ។

៤.២.៩.៤- ត្រូវបង់ប្រាក់ ០.១ សេនអាមេរិកក្នុង១នាទី សំរាប់គ្រប់ចរន្តសេវាតភ្ជាប់រវាងប្រព័ន្ធសម្រាប់ក្រសួងប.ទ. ។

## ៥- ការកត់ត្រាទិន្នន័យ និងការទូទាត់ប្រាក់

៥.១- រយៈពេលចាក់សំលេងផ្តល់ព័ត៌មានដល់អតិថិជនមិនត្រូវរាប់បញ្ចូលក្នុងការគិតប្រាក់ឡើយ ។

៥.២- គ្រប់ប្រតិបត្តិករត្រូវផ្តល់ចំនួននាទីសន្ទនាចូលនិងចេញប្រព័ន្ធខ្លួនជាមួយនិងប្រព័ន្ធទូរស័ព្ទនានាទាំងអស់ក្នុងកំឡុងពេល ១៥ថ្ងៃ បន្ទាប់ពីដំណាច់ខែនីមួយៗ ។

៥.៣- ប្រតិបត្តិករត្រូវផ្តល់ទិន្នន័យទៅក្រសួងទ.ប ជា Compact Disc ឬបញ្ជូនតាមខ្សែកាបដោយផ្ទាល់មិនអោយលើសជាង១៥ ថ្ងៃបន្ទាប់ពីដំណាច់ខែនីមួយៗ ។

៥.៤- ក្នុងករណីដែលប្រតិបត្តិករម្ខាងមិនផ្តល់ទិន្នន័យ និងបើពុំមានហេតុផលសមរម្យក្នុងការមិនផ្តល់ទិន្នន័យមេក្រសួងប.ទ. អាចចាត់ទុកទិន្នន័យម្ខាងទៀតជាត្រឹមត្រូវ ។

៥.៥- ការទូទាត់ប្រាក់រវាងប្រព័ន្ធពីរត្រូវធ្វើឡើងយ៉ាងយូរក្នុងរយៈពេល ៣ខែម្តង តែបើសិនមានការតវ៉ាលើប្រការណាមួយ ត្រូវធ្វើយ៉ាងយូ ១៥ ថ្ងៃក្រោយក្រសួងប.ទ បានបញ្ជាក់ថាត្រឹមត្រូវហើយ ។

៥.៦- ប្រតិបត្តិករត្រូវអនុវត្ត "គណនេយ្យផ្ទាល់" រវាងបណ្តាញដើម និងបណ្តាញចុងក្រោយ ។

## ៦- ការដាក់ពិន័យ និងថ្ងៃចូលជាធរមាន

៦.១- ប្រតិបត្តិករត្រូវបានផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌក្នុងករណីក្លែងបន្លំទិន្នន័យកត់ត្រាប្រចាំខែ និងអាចឈានទៅដល់ការដកហូតអជ្ញាប័ណ្ណសំរាប់ធ្វើអាជីវកម្មផង ។

៦.២- ប្រតិបត្តិករមួយមានសិទ្ធិផាកពិន័យជាការប្រាក់ ២% ក្នុងមួយខែសំរាប់ការយឺតយ៉ាវបង់ប្រាក់របស់ប្រតិបត្តិករជាភាគីម្ខាងទៀត ។

៦.៣- ប្រកាសនេះត្រូវអនុវត្តចាប់ពីថ្ងៃទី១ ខែមីនា ឆ្នាំ២០០០ នេះតទៅ ។

៦.៤- តម្លៃតភ្ជាប់ដែលមានចែងក្នុងប្រការ ៤-២ និងត្រូវកំណត់ជាថ្មីនៅពេលក្រសួងប.ទ. បានទទួលតួលេខតម្លៃចំណាយពិតប្រាកដពីប្រតិបត្តិករ ។

រដ្ឋមន្ត្រី

ប្រៃសណីយ៍ និងទូរគមនាគមន៍

សូ ឃុន

★★★